
PRIMERICA
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Celll: 267-984-8554
- Life Insurance
- Car Insurance
- Refinance Your Debts
- Investments
- Office or Home Appointment.
We also provide translation and interpretation services.
E-mail: 8665823172@primerica.gosolo.com
Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034



# ខ្មែរប៉ុស្តិ៍
# The Khmer Post
ISSUE 34 12th April-27th May 2009



ហាងមាសរស្មី
SUNSHINE JEWELRY INC
•Fine Jewelry
•Certified Diamonds & Custom Design

មានលក់គ្រឿង អលង្ការ យ៉ាងប្រណីតបំផុត
ពេជ្រសញ្ញាបត្រឈើពេជ្រអាច ឆ្លាក់ ឬ ច្នៃ
មាស ប្រាក់ ពេជ្រ ជូនតាមបំណង ។
702 Washington Avenue, Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com


## សកម្មភាពនៅហ្វីឡាដែលហ្វីយ៉ា

### ១. អគ្គបញ្ជាការខ្មែរ : KHMER COMMAND



●●●ព្រឹទ្ធាចារ្យខ្មែរជាច្រើននៅសហរដ្ឋអាមេរិកឆ្នេរខាងកើត បានបង្ហាញទឹកមុខ (តទៅទំព័រទី០៩)

## ពលរដ្ឋកម្ពុជា នាឱកាសចូលឆ្នាំឆ្លូវ

**ខ្មែរប៉ុស្តិ៍, ដោយ : ពិន សំខុន**

●ខ្ញុំអង្គុយផ្ចាត់ប្រក្រតីទិននាឱកាសចូលឆ្នាំ ព្រឹត្តិការណ៍ជាច្រើន បានកន្ត្រាក់អារម្មណ៍ឱ្យរំលឹកនូវភាពវិកវរនាអតីតកាលពីថ្ងៃ១៨ មីនា ១៩៧០ ថ្ងៃខួបនៃការទម្លាក់របប នរោត្តម សីហនុ រាជានិយម ដែលបានកាន់អំណាចយ៉ាងតឹងរឹងចំនួន៣៥ឆ្នាំ លើកម្ពុជា ជំនួសដោយរបបសាធារណរដ្ឋ ដឹកនាំដោយ លន់ នល់- ស៊ីសុវត្ថិ សារិមតៈ ។ (តទៅទំព័រទី១៨)

## ចូលឆ្នាំថ្មី : ល្បែងទាញព្រ័ត្រមានប្រយោជន៍
## ផ្នែកសិល្បៈ វប្បធម៌ សុខភាព និងកីឡា



●●●ល្បែងប្រជាប្រិយមានច្រើនប្រភេទណាស់ ដែលប្រជាពលរដ្ឋយើងនិយមលេងនៅពេលទំនេរពីការងារ ថ្ងៃបុណ្យប្រពៃណីជាតិ ក្នុងឱកាសថ្ងៃបុណ្យចូលឆ្នាំថ្មី ដើម្បីញ៉ាំងឱ្យពិធីនេះកាន់តែមានភាពសប្បាយរីករាយ និងមានភាពស្និតស្នាលថែមទៀត ។ (តទៅទំព័រទី០៧)

## ក្លឹបព័ត៌មានសំរាប់សហគមន៍ខ្មែរនៅហ្វីឡា

**ខ្មែរប៉ុស្តិ៍, ដោយ : អ៊ុំ ឈឿម**

●●●នេះជាលើកទីបីហើយដែលកាសែត **ខ្មែរប៉ុស្តិ៍** បានប្រារព្ធធ្វើសន្និសីទព័ត៌មាន (Press Club) ដែលមតិរបស់ពលរដ្ឋខ្មែរក្នុងសហគមន៍



ចាត់ទុកថា ជាទិវាដ៏មានសារៈប្រយោជន៍មួយសម្រាប់ផ្លោះប្តូរយោបល់ និងរកដំណោះស្រាយប្រយោជន៍ឱ្យសហគមន៍ខ្មែរដ៏តូចចង្អៀត និងជាសហគមន៍ ដែលល្បីខាងសំបូររឿងអាស្រូវជាងគេមួយនេះ ឱ្យមានភាពល្អប្រសើរជាងមុន។ គោលបំណង គឺផ្សារភ្ជាប់នូវភាពស្និតស្នាលរវាងពលរដ្ឋខ្មែរ ក្នុងសហគមន៍ហ្វីឡាដែលហ្វីយ៉ា ។

សន្និសីទព័ត៌មាន (Press Club) នេះត្រូវបានអញ្ជើញចូលរួមដោយភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ រួមប្រមាណជាង ៤០នាក់ ដោយថែម (តទៅទំព័រទី១០)


Mobile-net
We connect you to the world!
Since 1995

6.9¢
កម្ពុជា

ចុះឈ្មោះថ្ងៃនេះ នឹងទទួលបាន 133 នាទី សំរាប់ទូរស័ព្ទទៅកម្ពុជា ដោយឥតយកកំរៃ !
1.9¢ ថៃឡង់
5.5¢ ឡាវ
សេវាទូរស័ព្ទអន្តរជាតិ ដ៏ប្រសើរបំផុត
រកភ្នាក់ងារធ្វើការ
គ្មានកាលកំណត់
គ្មានយកកំរៃលើការតភ្ជាប់ប្រព័ន្ធ
គ្មានយកកំរៃលើការថែទាំ
គ្មានតម្លៃប្រែប្រួល
my011.com
1(800) 818-9000



ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ_អង្គរ
Angkor International Travel Agency
World Wide Travel & Tour Services
Cambodia – Vietnam – Laos – Thailand
(Since 1991)
USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
Cambodia: Victory Travel
No. 96 Eo Street. 148, Phsar Kandal
Phnom Penh, Cambodia
Tel: 011-892329
Manager SIN PO
CHENDA: 023-221069
Serving all Major air lines :
. SINGAPOR
. EVA AIR
. KOREAN AIRLINES
. MALAYSIA etc...

# ផ្កា ជើរី បូ្លសុម នៅរដ្ឋធានីវាស៊ីនតុន

ខ្មែរប៉ុស្តិ៍



●●●នៅរៀងរាល់ឆ្នាំ រដ្ឋធានី នៃសហរដ្ឋអាមេរិក តែងទទួលភ្ញៀវទេសចរ នៅថ្ងៃផ្កា **ជើរី បូ្លសុម** កំពុងរីកបណ្តាលឱ្យក្រុងទាំងមូលមានពណ៌សម្បុរសក្បុសគ្រប់ទិសទី ។ លើកនេះ ឆ្នាំ២០០៩ ផ្កាបានត្រូវរីកនាថ្ងៃទី៥ មុននេះ។

មនុស្សម្នាណែនកុ្កន់ដើរកំសាន្តជុំវិញបឹងព័ទ្ធអាគាររំលឹកគុណដល់លោក លិនតុន ដើមរុក្ខជាតិ ដែលមានតែផ្កាសក្បុសលំងបរិវេណដ៏ធំល្វឹងល្វើយ ត្រូវបានគេចង់ចាំថា ដើមរុក្ខជាតិអស់ទាំងនោះ គឺជាអំណោយរបស់ប្រទេសជប៉ុន ដែលមានចំនួន ៣០០០ដើម កាលពីឆ្នាំ ១៩១២ មកម្លេះ ។



បុគ្គលិកខ្មែរប៉ុស្តិ៍ ឆ្នេរខាងកើត ក៏បាននាំគ្នាទៅទស្សនាព្រឹត្តការណ៍ ដែលបានកើតឡើយតែមួយថ្ងៃ គឺថ្ងៃផ្ការីក នៅវ៉ាស៊ិនតុន ឌីស៊ី នោះដែរ ។

ខ្មែរប៉ុស្តិ៍


## ការិយាល័យច្បាប់របស់ ជេហ្វ្រី អិន ខែល



Law Offices of
Jeffrey N. Kale
Attorney at Law



ពិគ្រោះករណីច្បាប់ដោយមិនគិតកំរៃ យើងបានបំរើសេវាច្បាប់ជូនដល់សហគមន៍ខ្មែរជាង២០ឆ្នាំហើយ .ការិយាល័យ "ច្បាប់ទូទៅ" ដែលមានជំនាញផ្លូវច្បាប់ដូចតទៅ:

- ●គ្រោះថ្នាក់រថយន្ត
- ●បើកបរក្រោមឥទ្ធិពលស្រវឹង ឬពុល
- ●មានរបួសនៅកន្លែងធ្វើការ
- ●ទិញលក់អចលនវត្ថុ
- ●ច្បាប់បើកក្រុមហ៊ុន
- ●ច្បាប់ឧក្រិដ្ឋកម្ម
- ●គ្រោះថ្នាក់ដោយរអិល ឬដួល
- ●រំលោភច្បាប់លើផ្លូវចរាចរ
- ●ការទារឱ្យសងប្រាក់ជំពាក់ ។ល។

**New Jersey : 856-216-7171**
**1236 Brace Road, Suite K, Cherry Hill, NJ 08034**
**Pennsylvania/Philadelphia: 215-564-6900**
**1700 Sansom St., 3rd Floor, Street, Philadelphia, PA 19103**

**FREE CONSULTATIONS**
Providing legal services to the Cambodian community for 20 years
General Law Office specializing in the following areas of law:

| | |
|---|---|
| Car Accidents | Criminal Law |
| DUI/DWI | Slip & Fall Accidents |
| Workplace Injury | Traffic Violations |
| Real Estate | Collections |
| Corporate Law | |

សេវាច្បាប់ប្រកបដោយវិជ្ជាជីវៈ នឹងតម្លៃគួរសមអាចមានអ្នកបកប្រែជូនបាន





# ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300



សូមអញ្ជើញមកមជ្ឈមណ្ឌលធ្វើធ្មេញ "អាដាម" យើងធ្វើចុនពីដើមដល់ចប់បានយើងមានក្រុមទន្តបណ្ឌិត៥រូប ដែលមានជំនាញគ្រប់គ្រងក្រោយនៃវិជ្ជាធ្វើធ្មេញ ។

មណ្ឌលធ្មេញឯកទេស ខាងការងារលំអរ

ឯកទេសខាង
- ✓ Crowns,
- ✓ Braces,
- ✓ Bridges,
- ✓ Veneers,
- ✓ Inlay,
- ✓ Gold Caps,
- ✓ Implants,
- ✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅហ្វីឡាដែលហៀវតែមួយដែលមានបន្ទប់ពិសោធន៍ នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចប្តូរធ្មេញជំនួសដែលផលិតឡើងតាមគុណភាពដែលលោកអ្នកចង់បានទាំងអស់ សុទ្ធតែដំណើរការដោយបច្ចេកទេសវិជ្ជាជាន់ខ្ពស់ ហើយប្រើលំនាំប្រព័ន្ធ OSHA ជាក្បួន។

ទន្តសាស្ត្រទូទៅ
- -ដកធ្មេញ
- -បំពេញធ្មេញប្រហោង
- -ព្យាបាលប្រហោងដល់ឫសធ្មេញ
- -ផ្ចិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
- -**សំអាតធ្មេញឱ្យស្អាត:** ដោយធ្វើដោយឡេស៊័រមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
- -យើងក៏មានធ្វើការសំអាតដោយ "អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

បើកមជ្ឈមណ្ឌល

| | |
|---|---|
| ថ្ងៃ ច័ន្ទ | : 10am-6pm |
| ថ្ងៃ អង្គារ | : 10am-6pm |
| ថ្ងៃ ពុធ | : 10am-7pm. |
| ថ្ងៃ ព្រហស្បតិ៍ | : 10am-6pm |
| ថ្ងៃ សុក្រ | : 10am-6pm. |
| ថ្ងៃ សៅរ៍ | : 10am-7pm |

យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់
Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

ចុះថ្លៃ 10% ដល់អ្នកគ្មានប័ណ្ណសុខភាព

អាចធ្វើផែនការណ៍បង់ថ្លៃរាល់ខែ

# ពន្លកធម៌សាមគ្គីបានដុះហើយ

**កំណត់និពន្ធ :**

**•••លោក ម៉ម យិន អាយុ ៧៤ឆ្នាំ ជាសមាជិកគណបក្សសិទ្ធិមនុស្សផង ជាឧត្តមប្រឹក្សាកងកម្លាំង KHMER COMMAND ផង បានខិតខំស្វែងរក និងស្វែងយល់ពីកម្លាំងសាមគ្គីខ្មែរ ដោយប្រឹងប្រែង និងដោយបរិច្ចាកតែកម្លាំងនេះរកមិនបានសោះ ។ ទើបតែពេលនេះ ទោះជាគណបក្សប្រឆាំងទាំងពីរពុំទាន់ប្រកាសជាផ្លូវការក៏ដោយ លោក ម៉ម យិន បានឃើញពន្លឺនៃធមិសាមគ្គីកើតឡើងខ្លះហើយ... ។**

**ដោយ : ម៉ម យិន**

នៅក្នុងតំណាក់ការដែលខ្ញុំបាទត្រូវសម្រេចចិត្តនាំគ្រួសារចាកចេញពីមាតុភូមិខ្មែរ នាឆ្នាំ ១៩៩៣ ដោយសារតែសហរដ្ឋអាមេរិក បានអនុញ្ញាតឱ្យចូលមករស់នៅកសាងជីវិតថ្មី ទើបខ្ញុំបាទ បានប្ដេជ្ញាចិត្តជាថ្មីម្ដងទៀតថា ត្រូវតែត្រិះរិះពិចារណា សំឡឹងមើលលើបញ្ហាធំៗ ដែលកំពុងតែកើតមាននៅក្នុងប្រទេសខ្មែរ ចាប់តាំងពីសម័យក្រោយឯករាជ្យឆ្នាំ១៩៥៣ រហូតមកដល់សម័យជោគជ័យ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលជាសម័យមួយមានក្រុមមេដឹកនាំ តែងតាំងឡើងដោយកងកម្លាំងទ័ពប្រទេសជិតខាងមួយ ដែលក្រុមនោះឈ្មោះថា កងកម្លាំងទ័ពមហាយុទ្ធមិត្តសង្គមនិយមវៀតណាម ។

នៅក្នុងឆ្នាំ១៩៧៩ នេះហើយ ដែលទស្សនៈវិស័យរបស់ខ្ញុំបាទ មើលឃើញរូបភាពជាក់ស្ដែងលេចចេញមកពីថ្ងៃជោគជ័យ ៧ មករា ១៩៧៩ បានបង្ហាញអំពីកលល្បិចប្រកបដោយមហាគ្រោះថ្នាក់ធំបំផុតដល់វាសនានៃមាតុភូមិ និងជនជាតិខ្មែរ នៅក្នុងគ្រប់ស្រទាប់វណ្ណៈ តាំងពីលំដាប់ថ្នាក់ស្ដេចផែនដី មន្ត្រីគ្រប់ជាន់ថ្នាក់ អ្នកនយោបាយ បញ្ញាវន្ត សកម្មជន ព្រះសង្ឃ និងប្រជាពលរដ្ឋសាមញ្ញគ្រប់មជ្ឈដ្ឋាន ។

តួយ៉ាងមួយអំពីការបំបាក់បំបែកសាមគ្គីអ្នកនយោបាយ បញ្ញាវន្ត សកម្មជន ឃើញថា ក្រៅពីគណបក្សនយោបាយកាន់អំណាច គ្មានគណបក្សនយោបាយណាមួយ ដែលបានរីកចំរើន លូតលាស់ខាងធមិសាមគ្គី និងពង្រឹងពង្រីកឱ្យបានខ្លាំងរឹងមាំ ធំធាត់ទៅបានទេ ។ គណបក្សកាន់អំណាច មានចូលរួមនៅក្នុងគ្រប់ស្ថាប័នជាតិ នូវវរជនជាទីប្រឹក្សា និងអ្នកជំនាញការយួន ដែលបានក្លាយទៅជាមន្ត្រីរដ្ឋាភិបាល តំណាងរាស្ត្រ និងជាអ្នកគ្រប់គ្រងអង្គការរដ្ឋសំខាន់ៗអស់ទៅហើយ ។ រួចហើយបានអនុវត្តន៍ផែនការបំបែកបំបាក់សាមគ្គីនៃគណបក្សប្រឆាំងទាំងធំទាំងតូច ឱ្យបែកខ្ញាត់ខ្ញាយ ធ្លាក់ទៅជាខ្សោយ ដើម្បីធ្វើឱ្យគណបក្សកាន់អំណាចមានឱកាសកាន់អំណាចត្រួតត្រាជារៀងរហូតតទៅ ទោះជាមានអាណត្តិចំនួន ១០០ ក៏ត្រូវតែឈ្នះទាំង ១០០ ដែ រ ។

ទោះបីជាប្រជាពលរដ្ឋខ្មែរ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនាចំនួន ៩៥ ភាគរយ ហើយព្រះពុទ្ធបានប្រៀនប្រដៅថា ឱ្យត្រូវតែចេះចាំធមិសាមគ្គី ដូចជាហ្វូងព្រាប បានទៅជាប់ក្នុងលប់ពូកព្រាន រួចហើយបានរួចរស់ជីវិត ក៏ដោយសារតែហ្វូងព្រាបទាំងនោះ បានស្ដាប់តាមបញ្ជារបស់ព្រាប ពោធិសត្វ ឱ្យប្រើធមិសាមគ្គីរួមកម្លាំងគ្នាជាកម្លាំងតែមួយ ហើយស្ទុះហើរឡើងព្រមៗគ្នា ទាញយកទាំងលប់ឡើងទៅជាមួយផងទើបបណ្ដាលឱ្យហ្វូងព្រាបទាំងអស់បានរួចរស់ជីវិត ។

បើព្រះពុទ្ធអង្គបានប្រៀនប្រដៅដូច្នេះហើយ តើមកពីហេតុអ្វី បានជាតិខ្មែរ ពុទ្ធបរិស័ទ ៩៥% នេះ នៅតែបែកបាក់សាមគ្គីគ្នាដូច្នេះទៅវិញ ។

ពាក្យថា ធមិសាមគ្គី ដើម្បីឱ្យជនជាតិខ្មែរបានរស់រានជីវិតនោះ មិនមែនមានន័យថា នាំជនជាតិខ្មែរឱ្យទៅរួមសាមគ្គីជាមួយកងកម្លាំងទ័ពមហាយុទ្ធមិត្តសង្គមនិយមវៀតណាម យួននោះទេ ផ្ទុយទៅវិញ ត្រូវតែមានធមិសាមគ្គីរួបរួមគ្នាជាមួយអ្នកនយោបាយ បញ្ញាវន្ត សកម្មជនស្នេហាជាតិខ្មែរ ពិតប្រាកដនោះវិញទេ ទើបជាការល្អត្រឹមត្រូវ ។

ពន្លកនៃធមិសាមគ្គីជាតិខ្មែររួបរួមគ្នា បានផ្ដួចផ្ដើមដុះឡើងហើយ កាលពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៨ ដោយសារតែគណបក្សនយោបាយពីរ គឺគណបក្សសិទ្ធិមនុស្ស ដែលមានលោក កឹម សុខា ជាប្រធាន និងគណបក្ស សម រង្ស៊ី ដែលមានលោក សម រង្ស៊ី ជាប្រធាន បានជួបប្រជុំគ្នាធ្វើសន្និសីទកាសែតនៅចំពោះមុខអ្នកកាសែតជាតិ និងអន្តរជាតិ ក្នុងគោលបំណងថ្លែងប្រកាសអំពីការបង្កើតសម្ព័ន្ធភាពចូលគ្នារវាងគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី ឱ្យក្លាយទៅជាគណបក្សនយោបាយតែមួយ មានជំហរឈរលើគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងយុត្តិធមិសង្គមដូចគ្នា ។

បើសិនណាពន្លកនៃធមិសាមគ្គីនេះ បានដុះឡើងហើយចេះតែលូតលាស់មែននោះ សេចក្ដីសង្ឃឹមយ៉ាងមាំ ព្រមគ្នានិងសេចក្ដីពេញចិត្តប្រកបដោយសេចក្ដីត្រេកអរ សប្បាយរីករាយប្រាកដជាកើតមាននៅក្នុងបណ្ដាបញ្ញាវន្ត អ្នកនយោបាយ និងសកម្មជនស្នេហាជាតិខ្មែរទាំងអស់ នឹងងើបក្រោកឈរឡើង ជួយគាំទ្រ ជួយទំនុកបំរុង រហូតដល់បានជោគជ័យជាស្ថាពរ បង្កើតឱ្យបានជាកម្លាំងសាមគ្គីតែមួយ ដើម្បីជួយទ្រទ្រង់ ថែរក្សា ការពារប្រទេសជាតិ ពូជសាសន៍ខ្មែរ ឱ្យបានគង់វង្សស្ថិតស្ថេរចេរកាលជារៀងរហូតតទៅ ។

"សាមគ្គីជាតិខ្មែរ ជាកល្យាណមិត្ត
ជាសាមគ្គីត្រូវពិត នាំជីវិតរស់ ។
សាមគ្គីជាតិផ្សេង ជាមិត្តទុរយស
នាំជាតិខ្មែរឆ្ពោះ ដល់ក្ដីស្លាប់ពិត ។
"សាមគ្គីនិងអ្នកប្រាជ្ញបណ្ឌិត
សាមគ្គីត្រូវពិតជីវិតរស់
សាមគ្គីនិងចោរចិត្តទុរយស
សាមគ្គីនាំឆ្ពោះដល់ក្ដីស្លាប់ "៕


# BALDI FUNERAL HOME

1331 S. Broad St. Philadelphia, Pa 19147

Cell: 267-934-9888 / Tel : 215-389-2414

សូមសួររកលោក សេខ ឬ Thomas

**ឈាបនកិច្ចតាមប្រពៃណី**

ឈាបណដ្ឋានមានផ្ដល់ជូននូវក្ដារមឈូស ទីធ្លាសំរាប់បញ្ចុះ រៀបកំរងផ្កា និងសេវាឈាបណកិច្ចច្រើនប្រភេទ តម្លៃទៅតាមប្រភេទដែលត្រូវការសេវាឈាបណកិច្ចតាមវប្បធមិ និងតាមសាសនា និងបំពេញជូនជាកិត្តិយស យើងនឹងខំឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញសេចក្ដីត្រូវការ និងបំពេញប្រាថ្នារបស់លោកអ្នក ។

**ពិធីបូជាសព**

"បាល់ឌី" ផ្ដល់ជូននូវពិធីបូជាសពគ្រប់បែបជម្រើសរាប់ទាំងឱ្យភ្លើង ក្ដារមឈូសសំរាប់សពទន្ទឹមនោះមានសេវាពិធីបុណ្យតាមវប្បធមិ ការតម្កល់អដ្ឋិធាតុជាចុងបញ្ចប់ ។ មានជួយធ្វើលិខិតក្នុងករណីចង់នាំអដ្ឋិធាតុទៅកាន់ប្រទេសមួយទៀត មានចារឈ្មោះសពនៅលើទំព័រ "ខ្មែរប៉ុស្តិ៍" ជូនផង ។





(Locates in South Philly, convenience traffic, and free parking)

**Traditional Funeral**

Funeral Home provides caskets, cemetery space, floral arrangements, and funeral service options in various price ranges. Cultural and Religious funeral service is honored. We put full efforts to meet your needs and fulfill your wishes.

**Cremation**

Baldi offers complete cremation options including a combustible casket for the body, on site performing cultural memorial service, final placement of the cremated remains, paperwork assistance in case that need to transport the cremated remains to another country, and the Khmer Post newspaper notices.

# 17 មេសា របបសម្លាប់រង្គាល ព្រោះតែ 18 មីនា ?

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : មាជ សុវណ្ណារ៉ា**

●●●នៅថ្ងៃទី17 មេសា ឆ្នាំ 2009 នេះ រយៈពេល34ឆ្នាំ បានកន្លងផុតទៅនៃព្រឹត្តិការណ៍ដ៏ជូរចត់ពីសោកនាដកម្មកាប់សម្លាប់រង្គាលដល់ពលរដ្ឋប្រមាណ2លាននាក់ ពីសំណាក់ពួកខ្មែរក្រហមដែលខ្មែរគ្រប់រូបបានឆ្លងកាត់នាអំឡុងកាលនោះ នៅតែចងចាំ និងដក់ជាប់ក្នុងអារម្មណ៍ពីជីវិតអតីតកាលរបស់ខ្លួន ។ ចំណែករបបគ្រប់គ្រងមួយទៀត ហៅថា សាធារណរដ្ឋខ្មែរ ដែលបានរលាយសាបសូន្យទៅហើយ ក្រោយពីច្បាំងចាញ់កម្លាំងទ័ពព្រៃសម្ព័ន្ធមិត្តចម្រុះមានកងទ័ពយួនខាងជើងយួនវៀតកុងខ្មែរវៀតមិញ ទ័ពព្រៃ ស្មោះស្ម័គ្រនឹងសម្តេចព្រះនរោត្តម សីហនុ និងរួមជាមួយកងទ័ពខ្មែរក្រហម ប៉ុល ពត ។

ការកើតមានរបបកាប់សម្លាប់រង្គាលក្រោមនឹមត្រួតត្រាតាមបែបលទ្ធិកុម្មុយនីស្តម៉ៅនិយម ប៉ុល ពត ត្រូវបានអ្នកនយោបាយធ្លាប់បានគ្រប់គ្រងអំណាច និងកំពុងដឹកនាំប្រទេសសព្វថ្ងៃ ក៏ដោយបានចោទប្រកាន់ និងទម្លាក់កំហុសដាក់គ្នាពីមួយជំនាន់ទៅមួយជំនាន់ ដោយគ្មានអ្នកណាម្នាក់សារភាព ឬទទួលខុសត្រូវក្រៅតែពីការអួតអាងថា ខ្លួនដឹកនាំ និងធ្វើអ្វីៗសុទ្ធតែត្រឹមត្រូវទាំងអស់ Sic ។



(រូបថតឯកសារ)
សម្តេច សីហនុ ជាមួយនឹងក្រុមមេដឹកនាំខ្មែរក្រហមនៅតំបន់ព្រៃដែនភាគឥសានប្រទេស

មជ្ឈដ្ឋានខ្មែរដែលថា បានតស៊ូ ហើយបានជ័យជំនះចោទមេដឹកនាំសាធារណរដ្ឋខ្មែរថា ជាអ្នកផ្តើមនាំភ្នក់ភ្លើងសង្គ្រាមដុតនៅកម្ពុជានាដើមឆ្នាំ 1970 ។

នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ដែលបានរត់ចូលព្រៃតស៊ូជាមួយការអំពាវនាវរបស់សម្តេចនរោត្តម សីហនុ ពីទីក្រុងប៉េកាំងប្រទេសចិន កុម្មុយនីស្តបានថ្លែងជាសាធារណៈកន្លងទៅថ្មីៗនេះថា 18 មីនា អាចនិយាយបានថា ជាថ្ងៃប្រវត្តិសាស្ត្រនៃការបង្កើតសង្គ្រាមវិនាសកម្មនៅកម្ពុជា ។ នាយករដ្ឋមន្ត្រីខ្មែរ រូបនេះបានចោទប្រកាន់ថា បើគ្មានថ្ងៃ 18 មីនា ឆ្នាំ 1970 ក៏វា គ្មានរបបខ្មែរក្រហមកើតឡើង រហូតដល់មានការកាប់សម្លាប់រង្គាលដែរ ។

យោងតាមឯកសារប្រវត្តិសាស្ត្រដែលបានកត់ត្រាទុកបានបង្ហាញផ្ទុយពីការអះអាងរបស់លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ដោយឯកសារនោះបានបញ្ជាក់ថា អ្នកផ្តើមដុតភ្លើងសង្គ្រាមនៅកម្ពុជានាទសវត្សឆ្នាំ 1970 គឺពួកយួនខាងជើងយួនវៀតកុង ដោយមានក្រុមខ្មែររំដោះដើរតាមមាគ៌ានយោបាយសម្តេច សីហនុ និងក្រុមមាគ៌ាខ្មែរក្រហមដើរតាមកិច្ចដឹកនាំរបស់អតីតក្រុមបញ្ញវន្តស្រុកបារាំងមាន ប៉ុល ពត, អៀង សារី និង ខៀវ សំផន ដែលបានសហការគ្នាប្រយុទ្ធប្រឆាំងក្នុងសង្គ្រាម ដើម្បីផ្តួលរំលំរបបសេនាប្រមុខ លន់ នល់ ។

សម្តេចនរោត្តម សីហនុ ធ្លាប់មានព្រះរាជបន្ទូលកាលពីថ្ងៃទី23 មីនា ឆ្នាំ 1970 រហូតដល់ថ្ងៃទី 25 មីនា ឆ្នាំ 1971 ក្នុងការអំពាវនាវដាស់ស្មារតីប្រជារាស្ត្រខ្មែរឱ្យងើបឡើងតស៊ូប្រឆាំងនឹងរបប លន់ នល់ ដោយព្រះអង្គចោទប្រកាន់ថា របបសាធារណរដ្ឋខ្មែរដែលមានក្រុមអ្នកដឹកនាំធ្វើរដ្ឋប្រហារថា ជាក្រុមក្បត់ជាតិលក់ជាតិឱ្យចក្រពត្តិអាមេរិក ដើម្បីសម្លាប់ខ្មែរ ។ ក្នុងខណៈដែលសាធារណជនគិតថា ជាអំពើអយុត្តិធម៌ ព្រោះគ្មានពលរដ្ឋខ្មែរ អ្នករដ្ឋការទាហានណាមួយចេញមកជាសាធារណៈ ដើម្បីការពារ និងតបតទៅនឹងការចោទប្រកាន់ ។

សំរាប់ប្រវត្តិសាស្ត្រកម្ពុជាអ្នកស្រាវជ្រាវបានវាយតម្លៃថា ថ្ងៃ 18 មីនា ឆ្នាំ 1970 គឺជាថ្ងៃដែលសេនាប្រមុខ លន់ នល់ ដែលមានការគាំទ្រពីអាមេរិក បានធ្វើរដ្ឋប្រហារទម្លាក់

(តទៅទំព័រទី១៤)

NEW GOLDEN PALACE RESTAURANT
801-21 Washington Ave.
Phone: 215-627-2822
Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm
**Authentic Chinese & Vietnamese Cuisine**
**Very Delicious and Nutritious**
-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ
**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)
**ពិសេសដោយម្ចាស់ហាង:** មានចុះតម្លៃ **10%** លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ
**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement



Manager Special :
-10% OFF
LUNCH & DINNER
Present This Coupon

**ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)**
**Nam Vang Restaurant**
571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.
**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**
**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ដាំង ឆាសាច់គោ
- មីកន្ដាំងឆាគ្រឿងសមុទ្រ
- បាយឆាគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉ុងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់សេជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

# សាមគ្គីជាតិខ្មែរ

ខ្មែរប៉ុស្តិ៍, ដោយ : ម៉ម យិន




សាមគ្គីរួមគ្នាជាតិខ្មែរពិត សាមគ្គីពិសិដ្ឋជីវិតរស់
សាមគ្គីត្រូវណាស់មានកិត្តិយស សាមគ្គីលើកឈ្មោះក្រអូបសាយ ។
សាមគ្គីជាតិខ្មែរ ខ្មែរបានថ្កើង សាមគ្គីរុងរឿងភ្លឺពណ្ណរាយ
សាមគ្គីល្អណាស់ចិត្តរួមកាយ សាមគ្គីរីករាយកល្យាណមិត្ត ។
សាមគ្គីស្មោះត្រង់ចង់លើកជាតិ សាមគ្គីពេញខ្នាតជាខ្មែរពិត
សាមគ្គីត្រចះប្តូរជីវិត សាមគ្គីមូលមិត្តរិតស្រឡាញ់ ។
សាមគ្គីជាតិឯងតែងជោគជ័យ សាមគ្គីមានន័យមានចំណេញ
សាមគ្គីឈ្មោះថាបានបំពេញ សាមគ្គីរួមវេញខ្មែរតែមួយ ។
សូមមេត្តាដឹកនាំខ្មែរគ្រប់រូប ជ្រើសរើសកាន់យក ហើយលើកស្ទួយ
ធម៌សាមគ្គីពិតដែលអាចជួយ ជាតិខ្មែរផុតព្រួយផុតទុក្ខសោក ។
មិនត្រូវសាមគ្គីជាតិដទៃ នាំមកប្រល័យ ហើយឆបោក
ឱ្យខ្មែរបែកបាក់ធ្លាក់ទាបថោក ដោយចិត្តស្មោគគ្រោកគ្មានប្រណី ។
សូមខ្មែរទាំងអស់លើកឡើង ទើបជាតិខ្មែរយើងបានជោគជ័យ
បានជាតិរស់វិញ បានថ្លាថ្លៃ ចាប់តាំងពីថ្ងៃនេះទៅអើយ ៕

# ផលប្រយោជន៍ពីរប្រការ

## សាមគ្គីកល្យាណមិត្ត "១"

សាមគ្គីនិងកល្យាណមិត្ត សាមគ្គីល្អពិតជីវិតរស់
សាមគ្គីនេះល្អចិត្តសប្បុរស សាមគ្គីមានឈ្មោះក្រអូបសាយ ។
សាមគ្គីសាមគ្គានិងបណ្ឌិត សាមគ្គីរួមស្និទចិត្តរួមកាយ
សាមគ្គីនិងប្រាជ្ញអាចបានក្លាយ សាមគ្គីពណ្ណរាយបានជោគជ័យ ។
សាមគ្គីជាតិឯងតែបានសុខ សាមគ្គីផុតទុក្ខផុតសោកសៅ
សាមគ្គីនិងសាសន៍ល្អក្នុងលោក សាមគ្គីនាំមកសុខសាន្តអើយ ៕

## សាមគ្គីកមិត្តទុរយស "២"

សាមគ្គីនិងមិត្តចិត្តទុរយស សាមគ្គីនេះស្មោះទុក្ខឥតស្បើយ
សាមគ្គីនិងពាលចិត្តឡកឡើយ សាមគ្គីនេះហើយនាំវិនាស ។
សាមគ្គីសាមគ្គាមិនត្រូវត្រង់ សាមគ្គីអ្នកចង់ឱ្យនិរាស
សាមគ្គីនិងមនុស្សតែងឈ្នានីស សាមគ្គីឆាបឆេះក្តៅខ្លោចផ្សា ។
សាមគ្គីនិងមនុស្សមានល្បិចកល សាមគ្គីផ្តល់ផលសែនវេទនា
សាមគ្គីនិងអ្នកចិត្តពាលា សាមគ្គីនាំគ្នាសោយទុក្ខសោក ៕




ការិយាល័យមេធាវី លិនហ្សេ ដ័រេង

LAW OFFICE OF LINDSAY DOERING

ទទួលការពារផលប្រយោជន៍លោកអ្នកករណី ទូទៅតាមផ្លូវច្បាប់ដូចជា :
- ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
- ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសំបែង ដីធ្លីជាដើម ។
- ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ករណីអន្តោប្រវេសន៍
- ឬករណីឧក្រិដ្ឋកម្ម ។ល។



ធ្លាប់មានបទពិសោធន៍ខ្ពស់ ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។

General practice law office handling matters in :

Corporations and business Transations
Read Estate
Car Accidents
Work Place Injury
Immigration
Criminal Defense
Experienced, professional service and reasonable rate. Interpreter available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com

ឱសថស្ថាន ផ្លូវលេខ 8

វេជ្ជបណ្ឌិត អាឡិច លឿង

8th Street Pharmacy
Alex. N. Luong, RPh.

OPEN HOURS:
Mon. – Fri.: 9:00AM – 7:00PM
Sat.: 9:00AM – 5:00PM
Sun.: 9:00AM – 3:00PM

បើចង់បានសេវាថ្នាំពេទ្យឆាប់ សូមអញ្ជើញមករកអ្នកភូមិរបស់អ្នក គឺឱសថស្ថាន ផ្លូវលេខ ៨ (ជ្រុងផ្លូវលេខ៨ និង CHRISTIAN ហ្វីឡា- ខាងត្បូង)



- យើងទទួលប័ណ្ណមេឌីកែរ នឹងមេឌីខេត
- We Do accept Medicare & Medicaid
- We Do Offer Alternative Natural Medicines Including:
- យើងមានផ្តល់ជូននូវឱសថធម្មជាតិ មានដូចជា :
- Prostate -7 – ជួយដល់សុខភាព "ប្រស្តេដ" ដល់បុរស
- Pure Fresh Royal Jelly – ជួយលើកដំកើងនូវរសជាតិនៃជីវិត
- Fe-mon-9 – ជួយដល់ស្ត្រីនៅពេលមានអ័រម៉ូន
- Super Cross – ជួយបន្ថយការតាំងបេះដូង.ការលើសឈាម ឬកូឡេស្តេរ៉ូលច្រើន
- Gold Medal Swiss Placenta "សុកពពែស្វីស" មេដាយមាស សំរាប់កែសម្ផស្ស

819 S. 8th St.
Philadelphia, Pa 19147
Phone: 215-592-8888
Fax: 215-592-9888

តមកពីទំព័រទី០១

# ល្បែងទាញព្រ័ត្រមានប្រយោជន៍...

ចំណែកឯល្បែងទាញព្រ័ត្រគេសង្កេតឃើញពួកកំលោះ-ក្រមុំនៅតាមភូមិ-ស្រុក និងទីប្រជុំជននិយមចូលចិត្តលេងដោយសារតែវានាំមកនូវប្រយោជន៍យ៉ាងច្រើនដល់ពួកគេដូចជាផ្នែកកំសាន្តសប្បាយ សុខភាព កម្លាំងកាយ-ចិត្តជួយឱ្យមានសាច់ដុំមាំមួនរហ័សរហួន...។

លើសពីនេះទៀតល្បែងទាញព្រ័ត្រត្រូវបានគេនិយមលេងនៅតាមទីសាធារណៈដែលមានបរិវេណធំទូលាយ ដូចជានៅវាលស្រែ វត្តអារាម ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិជារៀងរាល់ឆ្នាំ ។

បុព្វបុរសយើងបានបង្កើតល្បែងប្រជាប្រិយប្លែកៗនៅតាមតំបន់នីមួយៗ សំរាប់ឱ្យកូនចៅលេងកំសាន្តសប្បាយជារៀងរាល់ឆ្នាំ នៅពេលទំនេរពីការងារ ពេលបុណ្យប្រពៃណីជាតិបុណ្យសាសនា... ។

ចំណែកល្បែងទាញព្រ័ត្រត្រូវបានចាស់ទុំយើងបង្កើតឡើងតាំងពីសម័យកាលដ៏យូរលង់ ហើយពួកកំលោះ-ក្រមុំនាំគ្នាលេងក្នុងចន្លោះខែ ចេត្រ ពិសាខ ពិសេសក្នុងថ្ងៃចូលឆ្នាំថ្មីដែលពួកគេនិយមលេងនៅតាមទីសាធារណៈណាដែលមានទីធ្លាធំទូលាយ ព្រោះល្បែងនេះត្រូវការមនុស្សចូលរួមលេងច្រើនគ្នាប្រើកម្លាំងខ្លាំងអស់ពីសមត្ថភាពរៀងៗខ្លួន ដើម្បីដណ្តើមយកជ័យជំនះឱ្យក្រុមរបស់ពួកគេ ។

ភាគីទាំងសងខាងស្រុះស្រួលគ្នាលេងល្បែងទាញព្រ័ត្រនៅពេលថ្ងៃ-ពេលយប់ ឬក្រោមពន្លឺព្រះចន្ទ ក្រោយពន្លឺចង្កៀងប្រេងកាត ឬភ្លើងអគ្គិសនីក៏មានដែរ ។ មុនពេលចាប់ផ្តើមលេងពួកគេបានជ្រើសរើសមនុស្សណាដែលមានមាឌធំកម្លាំងអាយុប្រហែលគ្នា ដោយក្រុមប្រកួតម្ខាងៗមានគ្នាចាប់ពី8ទៅ15នាក់ ឬច្រើនជាងនេះ ក៏បានដែរ គឺអាស្រ័យទៅលើចំនួនមនុស្ស និងការឯកភាពគ្នាទេ ។ ចំពោះការចែកជាក្រុមនេះ គេអាចឱ្យក្រុមម្ខាងសុទ្ធតែប្រុស ហើយម្ខាងទៀតសុទ្ធតែស្រី ដោយគេឱ្យស្រីមានគ្នាច្រើនជាងព្រោះមានកម្លាំងខ្សោយ អាស្រ័យទៅលើការព្រមព្រៀងគ្នារួចគេយកព្រ័ត្រធ្វើពីស្បែកគោ ឬក្របីដែលហាលស្ងួត ទំហំប៉ុន.កដៃដែលទាញទៅមិនដាច់មានបណ្តោយប្រវែងប្រមាណពី15ទៅ20ម៉ែត្រ ។

នៅពេលរៀបចំទាញយកឈ្នះចាញ់គេរកមនុស្សម្នាក់មកធ្វើជាអាជ្ញាកណ្តាល ដោយមានរគាំងមួយសំរាប់វាយជាសញ្ញា ឬស្គរសំរាប់ទះបើអត់មានទេ គេរាប់ពី1ដល់3ដោយមាត់ទទេទើបគេចាប់ផ្តើមប្រឹងទាញព្រមៗគ្នាឱ្យអស់ពីសមត្ថភាពឈ្នះ-ចាញ់រៀងៗខ្លួន ហើយគេធ្វើការសាកល្បងសមត្ថភាពម្តង ហើយម្តងទៀតរហូតអស់ចិត្ត ឬជូនកាលគេអាចដោះដូរកម្លាំង

(តនៅទំព័រទី១៦)


Washington Wellness Care

●បើលោកអ្នកមានគ្រោះថ្នាក់រថយន្ត. មានរបួសនៅកន្លែងធ្វើការ ឬក៏រអិល ហើយដួលរហូតដល់មានរបួសតែពុំដឹង នរណាជា អ្នកទទួលខុសត្រូវ ?






●យើងអាចជួយលោកអ្នកបាន

●មជ្ឈមណ្ឌល "វ៉ាស៊ីនតុនវែលណេសឃែ" មានបទពិសោធន៍ក្នុងរឿងរបួសក្នុងគ្រោះថ្នាក់រថយន្ត មានរបួសនៅកន្លែងធ្វើការនឹងរអិលដួលបណ្តាលឱ្យរបួស

●យើងណែនាំទៅមេធាវីដែលអាចការពារសិទ្ធិលោកអ្នកបាននៅពេលមានគ្រោះថ្នាក់

●អាចផ្តល់ផែនការណ៍ជួយចេញសោហ៊ុយចំពោះបុគ្គលដែលគ្មានប័ណ្ណធានារ៉ាប់រង

●សូមទូរស័ព្ទមក "វ៉ាស៊ិនតុនវែលខែល" ភ្លាម ដើម្បីឱ្យដឹងថា តើយើងអាចជួយលោកអ្នកដោយវិធីណា

វីតី និយាយភាសាខ្មែរ លេខទូរស័ព្ទ : 215-380-1350

500 Washington Ave., 1st Fl. Philadelphia, Pa 19147 Phone: 215-551-6838


# ព័ត៌មានពីប្រទេសថៃ : ខ្មែរ និង ថៃ កំពុងដណ្តើមគ្នាយកត្រូវ

ដោយ : ម៉ម យិន

•••នៅក្នុងការប្រយុទ្ធគ្នា នៅប្រាសាទព្រះវិហារ កាលពីថ្ងៃសុក្រ ទី៣ មេសា ឆ្នាំ២០០៩ មានការវាយប្រហារគ្នា រវាងកងទ័ពខ្មែរ និងកងទ័ពសៀម ដែលជាការប្រយុទ្ធលើកទី៣ តាំងតែមានវិបត្តិជម្លោះប្រាសាទព្រះវិហារ និងតំបន់ព្រំដែន កាលពីខែកក្កដា ឆ្នាំ២០០៨ មកនោះ។





ផ្សារ និងផ្ទះសំបែងរបស់ប្រជាពលរដ្ឋ ត្រូវទទួលរងខូចខាតនេះ បណ្តាលមកពីការប្រយុទ្ធគ្នារវាងទាហានខ្មែរ និងសៀម

ការប្រយុទ្ធគ្នានេះ បណ្តាលឱ្យមានការបាត់បង់ជីវិត និងរបួសទាហានមួយចំនួនទាំងសងខាង ដែលអាជ្ញាធរយោធានៃប្រទេសទាំងពីរ កំពុងចោទប្រកាន់គ្នាទៅវិញទៅមក ដោយពុំព្រមទទួលកំហុសថា ជាអ្នកបង្ករឿងមុនដំបូងនៃការប្រយុទ្ធគ្នាយ៉ាងសាហាវនោះឡើយ ។

ពលរដ្ឋសៀម មានប្រតិកម្មយ៉ាងខ្លាំង ផ្សាយពីបណ្តាញទូរទស្សន៍ថ្ងៃទី១ ឈ្មោះ ASTV NEWS 1 ដែលថា " ប៉ុន្មានឆ្នាំកន្លងមកនេះ ក្នុងសម័យរដ្ឋាភិបាលលោក តាក់ ស៊ិន ធ្វើជានាយករដ្ឋមន្ត្រី ក្រុមប្រឆាំងចាត់ទុកជានាយករដ្ឋមន្ត្រីមួយ បានប្រព្រឹត្តអំពើទុច្ចរិត ពុករលួយ ប្រើរបប ផ្តាច់ការ គតិតែផលប្រយោជន៍ផ្ទាល់ខ្លួន គ្រួសារខ្លួន " ។

តាមព័ត៌មាន ដែលផ្សព្វផ្សាយពីប្រទេសសៀមនេះ បានលើកឡើងអំពីបញ្ហាមួយចំនួនដែលទាក់ទងជាមួយនឹងនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ដោយចោទប្រកាន់ថា :

១- បានបង្កើតការបាញ់ប្រយុទ្ធគ្នា នៅតំបន់ប្រាសាទព្រះវិហារ នាថ្ងៃទី៣ មេសានេះ ។

២- បានរួមដៃជាមួយលោក តាក់ ស៊ិន ដែលនាំអ្នកមានទោសថៃ រត់គេចពីការតាមចាប់របស់តុលាការថៃ ។

៣- បានអនុញ្ញាតឱ្យលោក តាក់ ស៊ិន ចូលមកក្នុងប្រទេសខ្មែរ ហើយសព្វថ្ងៃកំពុងស្នាក់នៅក្នុងវិមានរបស់លោក ហ៊ុន សែន នេះតែម្តង ។

លោក តាក់ ស៊ិន បានប្រគល់លុយចំនួន ២០ លានដុល្លារ ទៅឱ្យលោក ហ៊ុន សែន ដើម្បីទិញអាវុធ យកទៅរៀបចំកងទ័ពព្រៃសៀម ទៅវាយប្រយុទ្ធយកខេត្ត ឈៀងម៉ៃ ឈៀងរ៉ៃ និងភូមិភាគឦសាន ផ្តាច់ចេញពីការគ្រប់គ្រងរបស់រដ្ឋាភិបាលសព្វថ្ងៃ ។

៥- គឺលោក ហ៊ុន សែន និងលោក តាក់ ស៊ិន នេះ កំពុងរៀបចំរួមគ្នា ដើម្បីការពារផលប្រយោជន៍ខ្លួន ក្នុងការរកស៊ីប្រកបមុខរបរធំៗ ដែលធ្លាប់មានទំនាក់ទំនងជាមួយគ្នា តាំងតែពីសម័យលោក តាក់ ស៊ិន នៅកាន់អំណាចមកម្ល៉េះ ហើយដែលលោកទាំងពីរ មានគោលបំណង និងគំនិតដូចគ្នា ក្នុងការប្រើអំណាចផ្តាច់ការ ប្រើអំពើទុច្ចរិត ពុករលួយដូចគ្នាបេះបិទទៀតផង ។

៦- បានចោទទៅលោក តាក់ ស៊ិន ថា ជាអតីតនាយករដ្ឋមន្ត្រី បានប្រគល់ប្រាសាទព្រះវិហារ ខេត្តកោះកុង និងដែនសមុទ្រប្រជុំកោះអាចម៍សេះ (ប៉ូលឡូវៃ) ដែលជារបស់ថៃ ទៅឱ្យប្រទេសខ្មែរ (Sic) ។

បញ្ហាសំខាន់ៗ មួយចំនួនខាងលើនេះ បណ្តាញទូរទស្សន៍ ASTV ថៃនេះ បានលើកយកមកផ្សព្វផ្សាយចាប់តាំងពីមុន និងក្រោយពេលវាយប្រយុទ្ធគ្នា នៅតំបន់ប្រលានឥន្ទ្រី និងជិតៗប្រាសាទព្រះវិហារ នៅពេលថ្មីៗ កន្លងទៅនេះ ។

កាសែតខ្មែរប៉ុស្តិ៍ សូមបញ្ជាក់ថា ការផ្សាយបណ្តាញទូរទស្សន៍ ASTV នេះ ជាការផ្សាយឯករាជ្យ មានប្រជាប្រិយភាពដល់ជនជាតិសៀមដែលរស់នៅក្នុង និងក្រៅប្រទេស តែនៅមានដំណឹងខ្លះ ត្រូវការប្រភពច្រើនទៀត ដើម្បីឱ្យអាចជឿបាន ។

ចំណែកប្រទេសខ្មែរ និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏ជាខ្មាំងសត្រូវរបស់ថៃដែរ នាពេលនេះដែរ ដូច្នេះហើយ បានជាទូរទស្សន៍ ASTV នេះ សុំអំពាវនាវទៅលោកនាយករដ្ឋមន្ត្រីថ្មី លោក អភិស៊ិទ វេឆាជីវ៉ាក់ ត្រូវតែទាក់ទងសួរទៅលោក ហ៊ុន សែន អំពីបញ្ហាខាងលើនេះ ។

កំណត់ចាត់ការ : សារព័ត៌មានខ្មែរប៉ុស្តិ៍ មិនអាចទទួលខុសត្រូវក្នុងការស្រង់ព័ត៌មានពីបណ្តាញទូរទស្សន៍ ASTV ថៃនេះថា ជាការពិត ឬមិនពិតបានទេ ៕



ប្រជាពលរដ្ឋភៀសខ្លួនចេញពីតំបន់ជម្លោះ

តមកពីទំព័រទី០៥

# ញត្តិថ្វាយព្រះ...

ឯយើងចាំតែទិញ ! យើងគួរតែនាំគ្នាគិតគូររឿងនេះ ដើម្បីជួយស្រុកយើងផង និងជួយខ្លួនយើងផង គួរតែនាំគ្នាស្វែងរកផលប្រយោជន៍របស់យើងឱ្យបានកុំទុកឱ្យផលប្រយោជន៍របស់យើងធ្លាក់ទៅក្នុងកណ្តាប់ដៃជាតិសាសន៍ដទៃតទៅទៀត ។

**ខ្មែរប៉ុស្តិ៍** បានស្ម័គ្រចិត្តទទួលនូវបេសកកម្ម នាំមុនទាំងនេះ ដោយពឹងពាក់ទៅលើសម្លេងស្រែករបស់ខ្លួន ដើម្បីរបមូលបងប្អូនរួមឈាមរបស់ខ្លួនឈរជ្រោងទង់តែមួយ ហើយបោះជំហានទៅមុខជាមួយគ្នាដោយស្វាហាប់ ។ តែអនិច្ចា ! **ខ្មែរប៉ុស្តិ៍** សឹងតែខ្យ័យធនទៅហើយ ។ ជាដំបូងក្រុម **ខ្មែរប៉ុស្តិ៍** ចេញដើមទុនខ្លួនឯង ដើម្បីផលិតសារព័ត៌មាននេះ ចែកជូនបងប្អូនយើងអានដោយឥតគិតថ្លៃ សង្ឃឹមទៅលើសោហ៊ុយ ដែលបានមកពីការផ្សាយពាណិជ្ជកម្ម យកទៅប៉ះប៉ូវការចំណាយលើការជួយវាយកុំព្យូទ័រ រៀបពុម្ព ទិញក្រដាសបោះពុម្ពផ្សាយ តម្លៃផ្ញើចែកចាយ ។ល។ ឱ្យដល់ដៃអ្នកអាន ។ ចំណែកឯអ្នកនិពន្ធ គឺចាំតែប្រឹងសរសេរដោយក្រដាសទឹកខ្មៅផ្ទាល់ខ្លួន ហើយផឹកទឹកកកសាបដោយលុយផ្ទាល់ខ្លួនទៀត ! ។ ឱ្យតែបានបុណ្ណឹងក៏ទ្រាំទ្រទៅមុខបានដែរ គឺធ្វើយ៉ាងម៉េចមានសារព័ត៌មាន មួយសម្រាប់ជាតិយើងបានទំនាក់ទំនងគ្នា ។

តែអកុសល តាំងពីសេដ្ឋកិច្ចនៅអាមេរិក ធ្លាក់ចុះមក អ្នកផ្សាយពាណិជ្ជកម្មខ្មែរ សុំដកចេញម្តងមួយៗ ព្រោះហាងគាត់បានបិតម្តងមួយៗ **ខ្មែរប៉ុស្តិ៍** ក៏ចង់រកខ្យល់មិនស្រួលដែរ ។ អញ្ចឹងហើយបានជាអំពាវនាវឱ្យបងប្អូនរួមជាតិ ខំជួយជាវប្រចាំខែ ប្រចាំឆ្នាំទៅ ដើម្បីឱ្យ **ខ្មែរប៉ុស្តិ៍** អាចបំរើបងប្អូនបានទៅទៀត ។ មិនមែនបុណ្ណឹងទេ ដើម្បីឱ្យសារព័ត៌មាននេះរស់បានតទៅទៀត យ៉ាងរឹងមាំ ដើម្បីបំពេញបេសកកម្មរបស់ខ្លួនខ្ញុំ បាទស្ម័គ្រនាំញត្តិមួយទៅថ្វាយព្រះឥន្ទ្រ ដើម្បីសុំឱ្យព្រះអង្គជួយប្រទានអំណោយខ្លះសម្រាប់ឆ្នាំ ឆ្លូវនេះ ។ ញត្តិមានសេចក្តីតទៅ :

សូមក្រាបបង្គំអង្គចេស្តារ　　ព្រហ្មវិហារធមិកំពូលភព
បង្គំចូលមកនៅក្រោមម្លប់　　ព្រះបារមីភពដោយហត្ថា ។
ទាំងពីរថ្វាយថ្វាត់ស្តេចមានឫទ្ធិ　　សូមប្រោសពិនិត្យដោយមេត្តា
បង្គំជាខ្ញុំភ័យតកមា　　ដាក់ទ្វេហត្ថាលើសិរសី ។
មេត្តាជាប្រទានដល់បង្គំ　　ប្រាក់រូបិព្រហ្មម្ចាស់សួគ៌ា
យកទៅទ្រទ្រង់ខ្មែរអ្នកជា　　ខ្មែរប៉ុស្តិ៍វេទនាមកយូរហើយ ។
សឹងតែខ្យ័យធនបះជើងច្រូង　　ដីហុយសំពោងគ្មានអ្នកទប់
បើមិនជួយទេពិតជាស្លាប់　　មេត្តាប្រញាប់សង្គ្រោះផង ។
ចង់មិនជួយលើកស្ទួយវប្បធម៌ជាតិ　　ខ្ទះខ្មែងខ្ចីឃ្មៀតឥតសំចៃ
ធ្វើកាសែតហ្វ្រីចែកដល់ដៃ　　សុំខ្មែរប្រុសស្រីអានគ្រប់គ្នា ។
ព្រោះចង់តម្កើងវប្បធម៌ជាតិ　　បាតជើងសព្រាតរកគេជួយ
តែគ្មានគេនាព្រះអង្គអើយ　　កាសែតចែកឱ្យទើបគាត់អាន ។
សុំគាត់ឱ្យជាវថា : ល្អៗ!　　បែខ្នងបត់កថា : "Bye Bye !"
ឱខ្មែរប៉ុស្តិ៍អើយគួរឱ្យស្តាយ　　កុំប្រាថ្នាឡើយឱ្យយើងជាវ ។
លុយគេស៊ូទុកចាយហ៊ុហា　　លងល្បែងស្រីស្រា ឬដល់មាន់
វាប្រសើរជាងណាអាភឿន!　　កុំឯងជឿនលឿនអានខ្មែរប៉ុស្តិ៍! ។
បើម្លឹងៗតើសង្ឃឹមអី?　　ព្រះឥន្ទ្រឥសីមេត្តាជួយ
ខ្មែរប៉ុស្តិ៍យើងខ្ញុំដេកតែព្រួយ　　រលំដួលហើយពីត្រឹមណឹង ។
ព្រះអង្គទ្រង់គង់លើស្បែនា　　ម្តចមិនមេត្តាទ្រង់ឆ្លងឆ្លើយ
ថាទ្រង់មេត្តាប្រទានឱ្យ　　ឬក៏បណ្តោយឱ្យបិទតូប? ។
បើមិនបានប្រាប់ស៊ូមិនទៅ　　សុខចិត្តក្រាញនៅក្បែរព្រះអង្គ
ក្រាប់ក្រាញនទៀលសុំឱ្យទ្រង់　　ហុចCheque មាbillion ទាល់តែបាន ។
បើមិនមេត្តាប្រទាន Cheque　　មេត្តាបញ្ជាក់អស់ទេវតា
នៅនាស្ថានព្រហ្មអាកាសា　　ជួយជាវដាក់ខែខ្មែរប៉ុស្តិ៍ផង ។

ព្រះព្រហ្មទ្រង់អនុញ្ញាតិឱ្យទេវតាមួយម៉ឺនលោកធាតុជួយជាវកាសែតខ្មែរប៉ុស្តិ៍ហើយ... !

ទូលព្រះបង្គំ សូមលាហើយ　　ឱ្យព្រះគុណអើយខ្ញុំអរណាស់
ឱ្យខ្ញុំព្រះអង្គក្រាបសំពះ　　ថ្វាយព្រះពរអស់ពីហឫទ័យ ។
សូមថ្វាយព្រះអង្គ ព្រះជាយា　　ព្រមទាំងទេវតាសព្វមន្ត្រី
ក្នុងឋានតាវតឹងសួគ៌ាល័យ　　ជួបជួនតែក្តីសុខសប្បាយ ។
សូមឱ្យព្រះអង្គល្បីខ្ចរខ្ចារ　　អស់ទាំងទិស្សានាភាល័យ
ទាំងចក្រវាលឡើភពទីទៃ　　ព្រះអង្គច្បាស់ល្បីព្រហ្មវិហារ ! ។
នាវាអាវកាសគេរង់ចាំ　　ឱ្យទូលបង្គំក្រាប់វន្ទារ
ឱនថ្វាយសំពះជំរាបលា　　អាម្រិកគេថា "Hi ! Bye Bey!" ។

## ជូនពរជនជាតិខេមរា

ឱបងប្អូនអើយជាតិខេមរា　　រស់នៅដែនដីក្រុងភីឡា
នាំគ្នាទះដៃសប្បាយអស្ចារ្យ　　ព្រោះយើងដឹងថាឆ្នាំថ្មីមកដល់ ។
ខ្ញុំសូមជូនពរសុខសួស្តី　　បងប្អូនប្រុសស្រីជាតិខេមរា
នៅលើទ្វីបលោកសព្វទិស្សា　　ឱ្យបានសុខាគ្រប់ៗប្រាណ ។
ចូរខំតែរកឱ្យមានបាន　　គ្រប់ៗតែប្រាណសង់ផ្ទះថ្ម
មិនមានប្រពន្ធខំស្វែងរ៉　　មិនមានសង្សាឱ្យខំប្រឹង ។
យើងជនជាតិខ្មែរពីត្រឹមណឹង　　ឆ្នាំឆ្លូវចូលរឹងយើងក្រោកព្រឹប
នាំគ្នាដាស់តឿនឱ្យគួរគិត　　ផ្លាស់ប្តូរគំនិតឱ្យបានឆាប់ ។
ខំរៀនខំសូត្រខ្លួននៅក្មេង　　ចាស់កុំនាំលេងតទៅទៀត
ប្រឹងប្រែងនាំគ្នាដោយខ្មីខ្មៀត　　ប្រឹងប្រែងឱ្យជាតិយើងថ្កុំថ្កើង ៕


ART OF WELLNESS CENTER



Art of Wellness
"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com



មន្ទីរសុខភាព "*Art of Wellness*" ទទួលព្យាបាលបញ្ហាផ្លូវចិត្តនឹងកាយធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នក របៀបបច្ចេកទេស និងបច្ចេកវិទ្យាបច្ចិមប្រទេស ។

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម:

- ធ្លាក់ទឹកចិត្ត DEPRESSION
- ការថប់អារម្មណ៍ ANXIETY
- ភាពតានតឹង STRESS
- មានកំហឹងច្រើន ANGER MANAGEMENT
- ឈឺខ្លួនប្រាណគ្រប់កន្លែង PAIN MANAGEMENT
- មានវិបត្តិក្នុងគ្រួសារ FAMILY ISSUES
- ការញៀន និងអ្វីមួយ ADDICTION ISSUES
- សុខភាពស្ត្រី WOMEN'S HEALTH

ទទួលព្យាបាលបានគ្រប់វ័យ

| របៀបព្យាបាល | TREATMENT TYPE |
|---|---|
| ប្រើម្ជុលឥតថ្នាំ | Acupuncture |
| ចាប់សរសៃ | Acupressure |
| ចិត្តវិទ្យា | Psychotherapy |
| យោគ/ ភាវនា | Yoga / Meditation |

វេជ្ជបណ្ឌិតនិងអ្នកជំនាញការមានបទពិសោធន៍ច្រើនឆ្នាំ នៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ៕

សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាពយើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល

ART OF WELLNESS CENTER
647 BAINBRIDGE SREET
PHILADELPHIA, PA 19147
215-305-2238

ភាសាខ្មែរទាក់ទង ប៊ុន រ៉ាត : 267-242-8526

(តមកពីទំព័រទី០១)

# សកម្មភាពនៅហ្វីឡា...

និងរូបរាងសង្ហារឡើងវិញ នៅពេលទទួលការអនុញ្ញាត្តិឱ្យរៀបចំឯកសណ្ឋានជាអតីតយោធា ហើយពាក់ឋានន្តរស័ក្តកិត្តិយសមកវិញ ។ នៅក្នុង កិច្ចប្រជុំមួយ កាលពីថ្ងៃអាទិត្យ ទី២៩ មីនា មុននេះ សមាជិកអតីតយុទ្ធជន ដែលនៅក្រោមផ្លាកសញ្ញាជាផ្លូវការឈ្មោះ KHMER COMMAND មានចំនួន ជាង៣០នាក់ បានបង្ហាញ ID



និងឯកសណ្ឋានរបស់ខ្លួនជាលើកដំបូងត្រៀមខ្លួនទទួលការបំពាក់ស័ក្តិ ដោយឧត្តមសេនីយ៍ BAUMANN មេបញ្ជាការ ជាន់ខ្ពស់នៃអង្គការ US VOLUNTEER JOIN SERVICE COMMAND USV-JSC ដែលបំរុងនឹងប្រព្រឹត្តទៅនៅថ្ងៃទី២ ខែឧសភា ខាងមុននេះ នៅហ្វីឡាដែលហ្វីយ៉ានេះ ។

លោក ថាច់ ខេមរិន្ទ បាននិយាយថា " អគ្គបញ្ជាការខ្មែរ ឬ KHMER COMMAND ពុំនៅក្រោមសាខារបស់អតីតរបស់យុទ្ធជនវៀត - ណាម ដែលមានចចាមអារ៉ាមនោះទេ គឺជាសាខាខ្មែរដាច់ដោយឡែកភ្ជាប់នឹងសមាគមអាមេរិកាំងតែម្តង " រីឯពាក្យថា " បើចូលជាសមាជិករបស់ KHMER COMMAND នេះហើយនឹងទទួល បានប្រាក់បំណាច់ ឬប្រាក់ខែអ្វីនោះ " លោក ថាច់ ខេមរិន្ទ បានបន្តថា " ជាការពុំពិតទេ លើកលែងតែអតីត យោធានោះបានបំរើកងទ័ពនៃ សហរដ្ឋអាមេរិក នៅក្នុងបញ្ជីឈ្មោះរបស់យោធាអាមេរិកាំង ទើបមានសិទ្ធិទាមទារបាន "។

លោក សិរិត ប៉ែន ជាអគ្គលេខាធិការបាននិយាយបន្ថែមថា " ក្នុងលក្ខន្តិករនៃសមាគម USV-JSC បាននិយាយថា ជនស៊ីវិលក៏អាចចូលរួមក្នុង KHMER COMMAND បានដែរ ឱ្យតែមានបំណងស្រឡាញ់ និងការពារកម្លាំងទ័ពការពារជាតិ " ។

លោក ម៉ម យិន ឧត្តមប្រឹក្សា KC បានស្នើឱ្យមានតែងតាំងអនុប្រធាន ហើយតំណែងនេះបានទៅលើ ជនី សុខ ដោយមានការយល់ព្រមពីអង្គប្រជុំ ។ (តទៅទំព័រទី១៤)


AMERICAN LEGION POST 153
PRESENTS



សូមអញ្ជើញមកកំសាន្ត ពិសារភេសជ្ជៈ
រាំកំសាន្តនៅ "ម្រាមទឹក"

FRANTIC
DJ FRIDAY AND SATURDAY
FROM 9 P.M. – 3 A.M.
MEMBERS ONLY
SMOKING PERMITTED

2514 S. 24TH ST.
PHILA., PA 19145
215-551-1950

បន្ធូរបរិយាកាសយ៉ាងត្រជាក់ចិត្ត
បន្ទាប់ពីធ្វើការខារហត់នឿយ !





• កន្លែងកំសាន្តធំទូលាយ-ស្តាប់ភ្លេងយ៉ាងពិរោះអស្ចារ្យ ឬកំបុកប៊ីយ៉ា ក៏មានជូនកំសាន្តដែរ ។
• យើងខ្ញុំរីករាយណាស់នឹងឃើញលោក-អ្នកអញ្ជើញមក !
• ថ្ងៃសុក្រ-សៅរ៍ ពីម៉ោង៩ដល់ម៉ោង៣ព្រឹក DJ នឹងបំពេញអារម្មណ៍ លោក-អ្នកតាមតន្ត្រីសំរាំងថ្មីៗ

ចង់ជួលសាល ឬចង់បានម្ហូបជប់លៀង យើងធ្វើជូនបាន !
HALL RENTAL & CATERING
AVALIABLE REASONABLE PRICE



CAMBODIAN ASSOCIATION OF GREATER PHILADELPHIA

តើអ្នកចង់បានការងារធ្វើនៅរដូវក្តៅនេះទេ ?
Do You Want a Summer Job ?



Spaces are limited! Jump on this opportunity right away to guarantee yourself a job this summer!

CAMBODIAN ASSOCIATION OF GREATER PHILADELPHIA
5412 North 5th Street
Philadelphia, PA 19120
Phone: 215-324-4070
Fax: 215-324-2995
Website: www.cagp.org

• បើសិនជាអ្នកមិនខ្លាចនឿយហត់នឹងធ្វើការទេ
• ប្រសិនបើអ្នកមានអាយុលើស ១៦ឆ្នាំ
• បើអ្នកកំពុងរៀននៅវិទ្យាល័យ តើអ្នកអាចធ្វើការ២០ ម៉ោង ក្នុងមួយអាទិត្យ ហើយរយៈពេល ៦អាទិត្យ នៅរដូវក្តៅនេះបានឬទេ ? បើបាន សូមប្រញាប់ទាក់ទង ទៅសមាគមខ្មែរ ព្រោះចំនួនការងារមានកំណត់ : សូមទំនាក់ទំនង មារលា លេខ 215-313 9298








Are you hardworking?
Are you over 16 years of age?
Are you a junior or senior in high school?
Can you work 20 hours a week for 6 weeks this summer?
Would you like to work in a small business setting?
Do you like to take advantage of great opportunities?!
Then, lets talk and be a part of our Summer Career Exploration Program!
Contact Mia-lia at 215-313-9298 or mialia@cagp.org





តមកពីទំព័រទី០១

# ក្លឹបព័ត៌មានសំរាប់សហគមន៍ខ្មែរ...

ទាំងមានវត្តមាននៃគណៈមេធាវីការពារក្ដីជនជាតិបរទេស, តំណាងឱ្យក្រុមពាណិជ្ជករខ្មែរនៅកំណាត់ផ្លូវលេខ៧, អង្គការសង្គមស៊ីវិល, តំណាងគណបក្សនយោបាយខ្មែរនានា ព្រមទាំងពលរដ្ឋខ្មែរក្នុងសហគមន៍មួយចំនួន ។ល។ ហើយកម្មវិធីនេះត្រូវបានប្រារព្ធធ្វើឡើងកាលពីថ្ងៃអាទិត្យ ទី២៩ ខែមីនា ឆ្នាំ២០០៩ កន្លងមក នៅឯភោជនីយដ្ឋាន Golden Palace ស្ថិតនៅលើវិថី Washington នាតំបន់ហ្វីឡាដែលហ្វីយ៉ាខាងត្បូង ។ មតិ និងសំណូមពរនានារបស់វាគ្មិនដែលបានចូលរួម :

លោក ប៉ែន សុវ័ណ្ណគីរី : ជាតំណាងពាណិជ្ជករខ្មែរលើកំណាត់ផ្លូវលេខ៧ និងជាពាណិជ្ជករដែលគេស្គាល់ថា ជាម្ចាស់ហាងលក់កាសែតចម្រៀងឈ្មោះ "មេគង្គវីដេអូ" បានសម្ដែងនូវទស្សនៈផ្ទាល់ខ្លួននាឱកាសនោះថា : សព្វថ្ងៃសកម្មភាពនៃការលក់ដូររបស់ពាណិជ្ជករខ្មែរនៅលើកំណាត់ផ្លូវលេខ៧ ហាក់មានការស្ងប់ស្ងាត់ជាងពេលមុនច្រើនណាស់ ព្រោះបណ្ដាលមកពីបញ្ហាការធ្លាក់ចុះនៃសេដ្ឋកិច្ច និងម្យ៉ាងដោយសារបងប្អូនខ្មែរមួយចំនួន ត្រូវប្រឈមនឹងការបញ្ឈប់ (Lay-off) ពីសំណាក់ក្រុមហ៊ុន និងបណ្ដាលមកពីមានការកាត់ម៉ោងធ្វើការជាដើម ។

លោក សុវ័ណ្ណគីរី បានបន្ថែមលើកត្តាសន្តិសុខនៅលើផ្លូវលេខ៧ យ៉ាងដូច្នេះថា : "ខាងសហគមន៍ខ្មែរ និងខាងវត្តផ្លូវលេខ៦ បានរៀបចំផ្នែកសន្តិសុខ ព្រមទាំងមានគម្រោងដាក់កាមេរ៉ាដើម្បីឱ្យអ្នកនៅរដ្ឋផ្សេងៗបានចូលចិត្តមក ព្រោះពួកល្បីថា ផ្លូវលេខ៧យើងមានការកាប់ចាក់, សម្លាប់ដូចជាឆ្នាំមុនៗ មានការសម្លាប់ស្ត្រីខ្មែរពីរនាក់អ៊ីចឹង, គេមើលតាមទស្សនាវដ្ដី, គេមើលតាមកាសែត, គេមើលតាម News អ៊ីចឹងទៅគេក៏ញញើតមកផ្លូវលេខ៧ដែរ " ។

ដោយឡែក លោក ហាន់វែន លីម ដែលបម្រើការនៅក្នុងអង្គការ SEAMAAC ក៏បានបានលើកយកបញ្ហាមួយចំនួនជម្រាបដល់អង្គ




សន្និសីទនាឱកាសនោះថា : នៅលើផ្លូវលេខ ៧ មានបញ្ហាច្រើនណាស់ មានទាំងចោរ, អ្នកលក់គ្រឿងញៀន និងមានទាំងបនល្បែងស៊ីសងជាដើម ។ ផ្លូវលេខ៧ គេស្គាល់ថា ជាតំបន់ដែលសំបូរទៅដោយហាងលក់ទំនិញរបស់បងប្អូនខ្មែរច្រើនជាងក្នុងទីក្រុងហ្វីឡាដែលហ្វីយ៉ា តែហាក់នៅពុំទាន់មានលក្ខណៈល្អគ្រប់គ្រាន់ដែលអាចទទួលយកបានទាំងស្រុងនៅឡើយពោល គឺនៅពុំទាន់បានល្អដល់កំរិតស្តង់ដានៅឡើយ ។ ប៉ុន្តែលោកបានសន្យាថា នឹងខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីឱ្យតំបន់ផ្លូវលេខ៧មានភាពល្អប្រសើរជាងមុនទៀត ។

មិនចំពោះតែពាណិជ្ជករ, អង្គការសង្គមស៊ីវិល, មេធាវី ។ល។ អង្គ-សន្និសីទ (Press Club) នេះ ក៏ត្រូវបានអញ្ជើញចូលរួមដោយប្រធានសាខាគណបក្សប្រឆាំងចំនួនពីរ គឺគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សផងដែរ ។



លោក ញ៉ូយ ចំរើន ប្រធានសាខាគណបក្សសិទ្ធិមនុស្ស ប្រចាំសហរដ្ឋអាមេរិក បានបញ្ចេញទស្សនៈថា : កម្មវិធីថ្ងៃនេះមានភាពល្អប្រសើរណាស់ ហើយក៏ជាការចាប់ផ្ដើមនូវភាពជោគជ័យសម្រាប់សហគមន៍ខ្មែរយើង




ជាពិសេសយើងបានជួបជុំគ្នា, យើងរាប់អានគ្នា និងផ្ដោះប្ដូរយោបល់គ្នាជាប្រយោជន៍ឱ្យមានរីកចម្រើនដល់សហគមន៍ខ្មែរយើង ។ ការដែលលោកអញ្ជើញមកចូលរួមក្នុងថ្ងៃនេះ មិនមែនក្នុងនាមជាគណបក្សនយោបាយទេ គឺក្នុងនាមជាពលរដ្ឋក្នុងសហគមន៍ធម្មតា និងជាវាគ្មិនរបស់អង្គពិធី ។

រីឯប្រធាន សហគមន៍ខ្មែរ ប្រចាំនៅតំបន់ហ្វីឡាដែលហ្វីយ៉ា លោក សម សិរិត បានផ្ដល់កិច្ចសម្ភាសន៍ដល់ខ្មែរប៉ុស្តិ៍ នាឱកាសនោះថា : នេះគឺជាបរិយាកាសដ៏ល្អ ដែលយើងបានជួបជុំគ្នា ស្និតស្នាលជាមួយគ្នា, ស្គាល់គ្នា" ។ លោក សិរិត បន្តថា: " កាលណាមកការជួបជុំគ្នាបែបនេះ ពិតជានាំមកនូវភាពចេះដឹងកាន់




តែច្រើនថែមទៀត ដូច្នេះយើងមិនត្រូវឱបដៃសម្ងំស្ងៀម ដោយមិនចូលរួមក្នុងកិច្ចការសង្គមនោះឡើយ ព្រោះកាលណាយើងមិនចូលប្រឡូកក្នុងសង្គមយើងពិតជាពុំបានជ្រាបអំពីភាពរីកចំរើនរបស់សហគមន៍ខ្មែរឡើយ ។

លោក សិរិត បានផ្ដាំផ្ញើរថា : ខាងសហគមន៍តែងតែប្រារព្ធធ្វើសិក្ខាសាលាប្រចាំខែជានិច្ច ហើយបើបងប្អូនខ្មែរចង់ជ្រាបអំពីព័ត៌មានលំអិតស្ដីអំពីដំណើរវិវឌ្ឍន៍របស់សហគមន៍ខ្មែរ សូមចូលទៅកាន់គេហទំព័រ www.cagp.org ។

ចំណែកលោក មាស ជា ប្រធានសាខា

(នៅទំព័រទី១១)






តមកពីទំព័រទី១០

# ក្លឹបព័ត៌មានសំរាប់សហគមន៍ខ្មែរ...


លោក មាស ជា

គណបក្ស សម រង្ស៊ី ប្រចាំរដ្ឋផែនស៊ីវ៉ៃនទៀ បានថ្លែងប្រាប់ក្នុងកិច្ចសម្ភាសន៍ជាមួយនឹង **ខ្មែរប៉ុស្តិ៍** ផងដែរថា : លោកចង់ដឹងថា : តើសន្និសីទសារព័ត៌មាននៅពេលនោះ មានអ្វីខ្លះសម្រាប់ឱ្យលោកយកត្រឡប់ទៅផ្ទះវិញ ? ។ លោក មាស ជា ក៏បានសំណូម ពរដល់ពលរដ្ឋខ្មែរក្នុងសហគមន៍ហ្វីឡាដែលហ្វីយ៉ា ទាំងអស់ឱ្យជួយយកចិត្តទុកដាក់លើកត្តាសន្តិសុខសង្គម, កត្តាសេដ្ឋកិច្ច, សុខភាព, នយោបាយ ។ល។ ពីព្រោះហ្វីឡាដែលហ្វីយ៉ា ជាផ្ទះសំបែងរបស់យើង។

អតីតប្រធានសមាគមខ្មែរ ហើយបច្ចុប្បន្នជាពាណិជ្ជករ ភ្នាក់ងារលក់ធានារ៉ាប់រង ឈ្មោះ ញ៉ូយ៉កឡាយ (New York Life) គឺ លោក ជិន វត្ថា ក៏បានសម្តែងនូវភាពរីករាយ ដែលលោកបានអញ្ជើញចូលរួមក្នុងជំនួបនាគ្រានោះ ។ លោក ជិន វត្ថា បានសម្តែងនូវអំណរគុណដល់កាសែត **ខ្មែរប៉ុស្តិ៍** ដែលបានផ្តួចផ្តើមឱ្យមានកម្មវិធី Press Club និងបានអញ្ជើញលោកឱ្យចូលរួម ។ ប៉ុន្តែ លោក វត្ថា មានទុដ្ឋិនិយមបន្តិច នៅត្រង់ពេលវេលាក្នុងការជួបជុំមិនសូវគ្រប់គ្រាន់ និងបរិយាកាសនៃអង្គសន្និសីទ Press Club ហាក់មានភាពអាប់អួរបន្តិច ព្រោះដោយការរំខានទានាពីភ្ញៀវដែលជាអតិថិជនទទួលទានភោជនាហារ នៅផ្នែកម្ខាងទៀត ដែលបង្កនូវសម្លេងសន្ទនាគ្នាពីនេះពីនោះ ស្ទើរពុំដាច់ស្នូរ។


លោក ជិន វត្ថា

អតីតប្រធានសមាគមខ្មែររូបនោះ បន្តថា : ចំពោះការបង្កើតឱ្យមាន Press Club បែបនេះ ជារឿងដែលសំខាន់ណាស់ ព្រោះជាការផ្តល់ឱកាសឱ្យបងប្អូនខ្មែរយើងបានជួបជុំគ្នាក្នុងគោលដៅពិភាក្សាអំពីបញ្ហាសង្គម ។ លោក វត្ថា បានបន្ថែមថា : សុំឱ្យបងប្អូនខ្មែរ ចូលរួមក្នុងកម្មវិធីបែបនេះឱ្យបានច្រើន ព្រោះនោះជាការចែករំលែកនូវចំណេះដឹងដល់គ្នា ជាពិសេសសូមជួយគាំទ្រដល់កាសែត **ខ្មែរប៉ុស្តិ៍** ផង ។

ឆ្លៀតក្នុងឱកាសនោះ លោក វត្ថា ក៏បានជូនពរដល់ពលរដ្ឋខ្មែរគ្រប់ៗរូបទាំងអស់ សូមឱ្យមានសិរីសួស្តី និងចេះស្រឡាញ់គ្នាថែមទៀត ។

លោក មេធាវី លិនស៊ី ជីវ៉ង បានទទួលភារកិច្ចមករាយការណ៍អំពីថវិការដ្ឋដ៏សន្ធឹកសន្ធាប់ចែកចាយ ដើម្បីជួយសង្គ្រោះសេដ្ឋកិច្ចពលរដ្ឋ និងសហគមន៍ជាតិ ដែលប្រាក់នោះឈ្មោះថា "Stimulus"។ ប្រាក់នេះមានចំនួនប្រមាណ ៧០០ពាន់លានដុល្លារ ដែលចែកជាប្រាក់ជួយដល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ជួយដល់ផ្នែកឧស្សាហកម្មជាតិ ជួយដល់បុគ្គលិករដ្ឋ និងឯកជនដែលកំពុងរងគ្រោះដោយសារវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរនាពេលបច្ចុប្បន្ននេះ ។


លោកមេធាវី លិនស៊ី ជីវ៉ង

អ្នកស្រី នារី គីត បានលើកពីករណីធ្លាក់ចុះនៃមុខរបររកស៊ីរបស់ខ្មែរ នៅតាមបណ្តោយផ្លូវអូលយ៉ក អ្នកស្រីក៏បានបន្ថែមទៀតថា WEDGE ដែលអ្នកធ្វើការ ស្ថិតនៅលើផ្លូវអូលយ៉កនោះ ហើយការិយាល័យនេះក៏អាចជួយបងប្អូនខ្មែរ ដែលត្រូវការកិច្ចព្យាបាលជំងឺផ្សេងៗរាប់ទាំងជំងឺសរសៃ ប្រសាទផងដែរ-មានជំនួយខាងផ្លូវច្បាប់អន្តោប្រវេសន៍ ឬការពិគ្រោះយោបល់គ្រួសារទៀតផង ។


អ្នកស្រី នារី គីត

លោក រឿត ចាត់ ធ្វើការនៅការិយាល័យមួយដែរ ដែលរកម្ចាស់ពាណិជ្ជកម្ម ឱ្យទទួលអ្នករស់ដោយរដ្ឋចិញ្ចឹមនោះ ឱ្យចូលទៅធ្វើការវិញ ដោយរដ្ឋធានាបង់ប្រាក់បៀវត្សរ៍ឱ្យ ១០០% ក្នុងរយៈពេលបីខែ ហើយ ៥០% ក្នុងរយៈពេលបីខែបន្ទាប់ ដោយសង្ឃឹមថា អ្នកធ្វើការនោះនឹងមានចំណេះដឹងគ្រាប់គ្រាន់សម្រាប់ឱ្យម្ចាស់ពាណិជ្ជកម្មនោះ ទទួលឱ្យធ្វើការជារហូតបាន ។


លោក រឿត ចាត់

សូមបញ្ជាក់ថា កម្មវិធី Press Club នេះត្រូវបានចាប់ផ្តើមនៅម៉ោង ១២:០០ថ្ងៃត្រង់ និងបញ្ចប់ទៅនៅម៉ោង ២:០០រសៀល ដោយបរិយាកាសរីករាយ ។ ក្រៅពីមានទទួលទាននូវភោជនាហារយ៉ាងឆ្ងាញ់ពិសារហើយនោះ លោក គីម ភឿន ដែលគេស្គាល់ថា ជាព្រឹទ្ធាចារ្យដែលសំបូរដោយរឿងកំប្លែងប្លែកៗ ក៏បានបានធ្វើឱ្យអ្នកចូលរួមផ្ទុះសំណើចសើចសប្បាយនាឱកាសនោះផងដែរ ៕


លោក គីម ភឿន



# Randolph C. Smith




## Attorney at Law

## 267-324-6503

**Office # 1**
**1819 JFK Blvd.**
**Philadelphia, Pa 19103**

**Office # 2**
**1115 S. 11th St.**
**Philadelphia, Pa 19147**

ការិយាល័យច្បាប់យើងខ្ញុំ មានចំនាញខាងករណី គ្រោះថ្នាក់រថយន្ត
☞ ការរបួសនៅកន្លែងធ្វើការ ☞ បើកបរក្រោមឥទ្ធិពលស្រវឹង
☞ ករណីឧក្រិដ្ឋកម្ម និងអន្តោប្រវេសន៍ យើងនឹងយកចិត្តទុកដាក់
ពីរថយន្តពីអ្វីទាំងអស់ដោយមិនឱ្យលោកអ្នកចំណាយប្រាក់ខ្លួនឯងឡើយ ។
បើចង់ដឹងអ្វីបន្ថែមសូមហៅរក **សុធា : (267) 324-6503**

We are specialty in Car Accident, Work Injury, DUI, Criminal Matter, and Imminration.

We will take care of your car and everything else without your pochet expense.
Please contact Sothia at 267-324-6503 for more information.

# The Noni Juice

ទឹកផ្លែមផ្លែ"ណូនី"ខ្មែរហៅផ្លែ"ញ"ត្រូវគេចងចាំថា ឪពុកម្តាយ ឬដូនតា ធ្លាប់យកផ្លែ "ញ" នេះទៅត្រាំស្រា ហើយពិសារជាថ្នាំព្យាបាលការឈឺចុកចាប់នានា បណ្តាលឱ្យមានកម្លាំង-ចុះកម្លាំងឈាម ។ល។ ឥឡូវនេះ អ្នកវិទ្យាសាស្ត្រខាងពេទ្យរកឃើញថា ផ្លែ"ញ" នេះ បើប្រើឱ្យសុទ្ធគ្មានលាយជាតិគីមីនឹងធ្វើឱ្យចុះសម្ពាធឈាមបន្ថយការឈឺសន្លាក់ឆ្អឹងព្យាបាលជំងឺទឹកនោមផ្អែម-ធ្វើឱ្យមានកម្លាំង និងជួយរំលាយអាហារទៀតផង។
សូមទាក់ទងតាមឈ្មោះ និងទូរស័ព្ទខាងក្រោម ដើម្បីជាវទឹកផ្លែម"ណូនី"




Philadelphia: David: 215-268-4821 or Jason: 215-805-3396
Rhode Island: Hui Le: 401-640-5158
Lowell: Samran: 508-216-6062

The Noni Jucie is made by traditional method, 100% pure, and no preservation. It can help decrease high blood pressure; reduce arthritis pain, diabetes, increase body energy level and digestion system.




# ខ្មែរអង្គរ Gift Shop

*Cambodian Traditional & modern high-end custom design*



"សូមអញ្ជើញអ្នកនាងកញ្ញានឹងអស់លោក មកស្វែងរកមើលសំលៀកបំពាក់តាមប្រពៃណីនឹងតាមសម័យថ្មីរបស់ខ្មែរ តួសនឹងកាត់ដេរកំរិតខ្ពស់ តាមបំណងនឹងក្តីស្រមៃរបស់អ្នកនាងកញ្ញានឹងអស់លោកបាន ។ នាងខ្ញុំជឿថា : អ្នកនាងកញ្ញា អាចរកនូវសំពត់ អាវ នៃក្តីស្រមៃបាន សំពត់ ដែលវិប្បធម៌ដ៏ព្រកាលនៃសតវត្សរ៍ដ៏រុងរឿងមកគ្របដណ្តប់រូបរាងកាយអ្នកនាងកញ្ញា នេះជាការយល់សប្តិស្មានមិនដល់ ថាអាចកើតឡើងបាន" ... ស៊ីនួន






*Men & Women Casual Wear, Accessories, Khmer Videos & DVDs.Alteration Service Only $6.00*

**1541 S. 5th Street**
**Philadelphia, Pa 19148(267)639-3400**

តមកពីទំព័រទី០៧

# ល្បែងទាញព្រ័ត្រមានប្រយោជន៍...

គ្នាទៅវិញទៅមកធ្វើយ៉ាងណាឱ្យមានតុល្យភាព ។

ការប្រកួតយកឈ្នះ-ចាញ់នេះ គេមិនមានគំនុំព្យាបាទឈ្លោះប្រកែកគ្នាបង្កការលំបាកដល់បក្ខពួក និងក្រុមគ្រួសារនោះទេ គឺពួកគេគ្រាន់តែសាកល្បងសមត្ថភាពដើម្បីការសប្បាយរីករាយបង្កើនកម្លាំងក្នុងខ្លួន ដើម្បីឱ្យមានសុខភាពមាំមួន កម្លាំងខ្លាំងក្លា ហូបបាយបានសំរានលក់ហាត់ពត់ទឹកចិត្តឱ្យចេះតស៊ូអំណត់ចេះប្រើល្បិចកលប្រាជ្ញាស្មារតីចេះដោះស្រាយឧបសគ្គនៅចំពោះមុខទាន់ពេលវេលាប្រកបដោយជោគជ័យ... ។

ទាក់ទិននឹងល្បែងនេះ តាមសៀវភៅល្បែងប្រជាប្រិយដែលរៀបរៀងឡើងដោយលោក ចាប ពិន, អ្នកស្រី ពេជ្រ សល់, លោក លី ឆាមតេង និងលោក ស្ដើង ធូរ បានបញ្ជាក់ថា :

មុនដំបូងគេរើសរកប្រុសម្នាក់ស្រីម្នាក់មានមាឌមាំធំ ស្វាគាង កម្លាំងខ្លាំងជាអ្នកឈរកាន់ចុងព្រ័ត្រ គឺប្រុសកាន់ចុងម្ខាង ស្រីកាន់ចុងម្ខាង ហើយឱ្យប្រុសម្នាក់ ស្រីម្នាក់ទៀតមានមាឌធំមានកម្លាំងឈរកណ្ដាលព្រ័ត្រត្រង់កន្លែងដែលពួកទាំងពីរឈរសម្រាប់ជាតំណាងពួកខ្លួនឱ្យខទាញតែរៀងៗខ្លួន ឯមនុស្សមានមាឌតូចៗស្គមៗកម្លាំងខ្សោយៗគេឱ្យឈរកណ្ដាលគេ ។ លុះរៀបចំរួចហើយគេឱ្យមនុស្សប្រុសម្នាក់កាន់សម្ពោរ ឬគងម៉ង់ ឬរគាំងឈរត្រង់កណ្ដាលទីជិតអ្នកទាំងពីរដែលកាន់ឈរប្រទល់មុខគ្នានោះផ្ដើមស្រែកឡើងថា យក្សអរ !! ឮយ៉ាងខ្លាំងៗ ធ្វើសំឡេងវែងៗរលាក់រលែកយ៉ាងគ្រលួច ។

ឯអ្នកទាញព្រ័ត្រទាំងប៉ុន្មានជួយស្រែកទទួល



ឡើងព្រមគ្នាថា ហ៊ោរ៉ិៗ3ដង ទើបនាំគ្នាទាញដើម្បីយកជ័យជំនះតែរៀងខ្លួន ។ ក្នុងពេលពួកអ្នកទាញព្រ័ត្រកំពុងតែខំប្រឹងទាញអ្នកកាន់សម្ពោរ ឬគងម៉ង់ ឬក៏រគាំងគេចេះតែបញ្ចើចសម្ពោរ ឬគងម៉ង់ ឬក៏រគាំងរឿយៗ ឮសូរតាក់ទីងៗ ឬម៉ូងៗម៉ីងៗជាដរាបទាល់តែឃើញចាញ់ឃើញឈ្នះម្ខាងៗទើបឈប់បញ្ចើច ។

ពេលលេងម្ដងៗអស់ថេរវេលាពី5-6នាទីដល់10នាទីឡើងទៅទើបឃើញឈ្នះឃើញចាញ់ម្ខាងៗ ។ កាលដឹងថា ខាងណាឈ្នះហើយគេចាប់ផ្ដើមលេងសាជាថ្មីតទៅទៀត ដរាបហត់តែរៀងៗខ្លួនទើបឈប់ ។

ល្បែងទាញព្រ័ត្រ បើតាមការសាកសួរពីចាស់ទុំនៅតាមតំបន់ផ្សេងៗគ្នាថា មានអាយុកាលរាប់សិបឆ្នាំមកហើយ ត្រូវបានកូនចៅនិយមលេងតៗគ្នារហូតមកព្រមទាំងមានប្រជាប្រិយ-ភាពទៀតផង ការបង្កើតល្បែងប្រជាប្រិយនេះឡើងក្នុងគោលបំណងបង្កើនទំនាក់ទំនងសាមគ្គី

(តទៅទំព័រទី៣៩)

ភាពរវាងពួកយុវវ័យដែលរស់នៅផ្ទះជិតគ្នាក្នុងភូមិផងរបងជាមួយចេះស្រឡាញ់វិស័យកីឡាស្រឡាញ់សុខភាព និងបង្កើនសមត្ថភាពរាងកាយឱ្យមាំមួន ចេះតស៊ូអំណត់ចំពោះការងារមានភាពរហ័សរហួនក៏ដូចជាលើកស្ទួយវិស័យវប្បធម៌សិល្បៈ និងកីឡាផងដែរ ។

លើសពីនេះទៀត ត្រូវទទួលការនិយមគាំទ្រពីសំណាក់យុវវ័យគ្រប់មជ្ឈដ្ឋាន ព្រមទាំងនិយមលេងក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិផ្សេងទៀតផង ។ ប៉ុន្តែសព្វថ្ងៃដោយសារតែវិស័យសិល្បៈទី7 វិទ្យាសាស្ត្របច្ចេកទេសមានការរីកចំរើនខ្លាំង ល្បែងទាញព្រ័ត្រមានការស្រុតចុះ ហើយនិយមលេងនៅតែតាមតំបន់មួយចំនួនប៉ុណ្ណោះ ។

លោកបណ្ឌិត មីសែល ត្រាណេ អ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកបុរាណវិទ្យា បានមានប្រសាសន៍ថា ល្បែងទាញព្រ័ត្រនោះមានកំណើតតាំងពីសម័យបុរាណសម័យមុនអង្គរ ឬសម័យអង្គរ ដែលពួកយុវវ័យយើងលេងនៅតាមទីវត្តអារាម ភូមិ-ឃុំ នៅពេលទំនេរពីការងារ និងពិធីបុណ្យទានម្ដងៗ ។

លោកបណ្ឌិត មីសែល ត្រាណេ បានបន្តថា ល្បែងនោះវាបានរួមចំណែកលើកស្ទួយផ្នែកសុខ-ភាព កីឡា និងវប្បធម៌ខ្មែរផងដែរ ។ ជាពិសេសបុព្វបុរសយើងបានឆ្លាក់ល្បែងនេះនៅតាមជញ្ជាំងប្រាសាទ និងខ្លោងទ្វារអង្គរធំផងដែរ ៕


From :Philadelphia



សួស្តីឆ្នាំថ្មី

ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe`s Auto Service**




State and Emission Inspection General Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរប្រ៊្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងក៏រត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្ដេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376



**ANGKOR AUTO SERVICE, INC.**

ហាងជួសជុលរថយន្ត "អង្គរ"

4835 N. 16th Street. Tel : (215) 455-7810
Philadelphia, Pa 19141 Ricky : (215) 485-1425

Specializing in Body Kit and Custom Paint

ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ិនស៊ូរិន បានផង
យើងផ្ដល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C






បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើមកបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

(តមកពីទំព័រទី១៤)

## អតីតយុទ្ធជនខ្មែរ...

exist in their new homes. The Unites States Volunteers- Joint Services Command makes it possible for Cambodia's military men and women to be recognized for their services. The USV-JSC Khmer Command seeks to educate and inform younger generations of their sacrifices and love of one's own country. As members of The United States Volunteers- Joint Services Command, they will able to pass down the importance of instilling patriotism and volunteerism with many Cambodian-Americans.

**Bopea Chum**

### ២. កូនសិស្សសាលា$E_3$ បង្ហាញម៉ូតខោអាវខ្មែរ

នាឱកាសចូលឆ្នាំខ្មែរខាងមុនសិស្សានុសិស្សខ្មែរ នៅសាលា$E_3$ POWER CENTER នឹងធ្វើការបង្ហាញម៉ូតសំពត់អាវខ្មែរ នាឱកាសចូលឆ្នាំខ្មែរ ថ្ងៃទី១៥ មេសា ខាងមុននេះ ។ ឆាណាម៉ារាឌី- សុគន្ធា និង ជេនីកា បាននាំគ្នាត្រៀមខ្លួននឹងបង្ហាញម៉ូតតាមរយៈកម្មវិធី ពហុវប្បធម៌ ដោយមានសិស្សជាតិសាស្ត្រអាមេរិកាំងចូលរួមផងដែរ ។

សមាគមន៍ខ្មែរ នៅឡូគ្គាន់ បានជួយយ៉ាងសកម្មញ៉ាំងឱ្យការងារសិល្បៈខ្មែររបស់យុវនារីខ្មែរនេះ អាចប្រព្រឹត្តទៅបានប្រសើរតាមថ្ងៃកំណត់ ។ សហគមន៍ខ្មែរ និងបរទេស អាចនឹងអញ្ជើញទៅចូលរួមអបអរសាទរស្នាដៃកូនខ្មែរ និងកូនអាមេរិកាំងរួមគ្នាបានដោយសេរី នៅថ្ងៃទី១៥ មេសា ២០០៩ វេលាម៉ោង ១២ ដល់ម៉ោងពារសៀល ៕


សាលារៀន "ឡូហ្គានហូប"
LOGAN HOPE

Low cost, quality education in small classes Join us for K or 1st grade in September LOGAN Hope School
4934 N 13th St . Philadelphia, PA 19141
Tel : (215) 455-7442

ហាងម្ចាស់ នួន វីដេអូ សូមស្វាគមន៍
នាឱកាសចូលឆ្នាំថ្មី 2009
មានលក់ CD VCD & DVD
MCHAS NOUN VIDEO
647 RITNER ST. PHILADELPHIA, PA 19148
Tel : (215) 465-0464
ម្ចាស់នួន វីដេអូ MACHAS NUON VIDEO
Clothes, Video Rental, Accessories
647 RITNER STREET TEL. 215-465-0464

យើងខ្ញុំមានលក់សំលៀកបំពាក់ប្រពៃណីខ្មែរ និងម៉ូដទាន់សម័យសំរាប់ចូលរួមពិធីផ្សេងៗមាន CD ,DVD និងមានរបស់របរច្រើនមុខទៀត ។


ប្រសិនបើសំលៀកបំពាក់ដែលបងប្អូនទិញ ហើយពាក់មិនត្រូវទេ យើងអាចកែរជូនដោយឥតយកកំរៃ យើងក៏មានទទួលកាត់ដេរខោ និងកែសម្រួលសំលៀកបំពាក់ដែលលោកអ្នកនាំមកពីក្រៅហាង យើងខ្ញុំយកតំលៃសមរម្យ ។

ផ្កាយព្រឹក វីដេអូ
PKAY PREK VIDEO
(215) 455-2762
4935 OLD YORK RD. PHILADELPHIA, PA 19141


ជួលកុន_លក់ឌីវីឌី និង ស៊ីឌី
MOVIE RENTAL
DVD & CD SALES
CAMBODIAN FORMAL DRESSES
WOMEN & BABY CASUAL WEARS

Sav-Mor PHARMACY
Tel: 215-467-1220
ឱសថស្ថានខ្មែរ

Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447
បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត
- Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.


ក្រុមហ៊ុន ទេសចរណ៍
CENTURY TRAVEL & SERVICE CENTER
904 South 8th Street. Philadelphia, Pa 19147
Tel. 215.625.2889 – Fax. 215.625.9395
Cell: 267.934.9888 – email: centuryphl@yahoo.com
- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M
- Serve all Airlines
- National & International flights
- Khmer Passport Extension
- Immigration
- Tourist Visa
- Money Transfer
- Notary Public

We speak Khmer, Chinese Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន វៀតណាម

គណបក្សសិទ្ធិមនុស្ស
បំរើ-ការពារ-កសាង
HUMAN RIGHTS PARTY

ដឹកនាំដោយឯកឧត្តម កឹម សុខា
សូមអញ្ជើញលោក.លោកស្រីមើលក្នុងគេហទំព័រ www.HRPCambodia.info ដើម្បីស្តាប់វិទ្យុ និងតាមដានព័ត៌មានទាន់សភាពការណ៍ ទាក់ទងនឹងប្រទេសកម្ពុជា ។
បើអស់លោកចង់ចូលរួម សូមទាក់ទងមក
លោក ញ៉ាយ ចំរើន ទូរស័ព្ទ :
267-226-7861 អ៊ីម៉ែល : chamroeunkh@yahoo.com

**United States Volunteers Joint Services Command**
**Khmer Command (អគ្គមេបញ្ជាការដ្ឋានខ្មែរ)**

## សេចក្តីប្រកាសនិងជំរាបជូន

យើងខ្ញុំជាគណៈកម្មាធិការ អគ្គមេបញ្ជាការដ្ឋានខ្មែរ មានសេចក្តីប្រកាស និង ជំរាបជូនដល់បងប្អូនខ្មែររួមជាតិទាំងអស់ ដែលរស់នៅក្នុងទឹកដីសហរដ្ឋអាមេរិកទាំងមូលថា: យើងខ្ញុំបានរៀបចំពិធីលើកកិត្តិយសដល់ នាយទាហាន នាយទាហានរង ពលទាហាន ដែលនៅសេសសល់ ហើយក៏ធ្លាប់បានចូលរួមប្រយុទ្ធយ៉ាងខ្លាំង ក្នុងសមរភូមិជាមួយកងទ័ពសហរដ្ឋអាមេរិក ពេលនេះយើងទាំងអស់គ្នា ទើបបានទទួលនូវកិត្តិយសយ៉ាងកក់ក្តៅចេញពី ក្រសួងការពារជាតិ នៃសហរដ្ឋអាមេរិក ដែលមានឈ្មោះថា: **United States Volunteers Joint Services Command** និងធ្វើពិធីផ្តល់កិត្តិយស បំពាក់ឋានន្តរសក្តិ ដល់អ្នកដែលធ្លាប់មានគុណបំណាច់ ចំពោះប្រទេសជាតិខ្មែរ នាសម័យសាធារណរដ្ឋខ្មែរ ដើម្បីផ្តល់ការលើកទឹកចិត្ត និងចង់ឃើញនូវព្រឹត្តិការណ៍ថ្មីៗនេះ ដូច្នេះសូមអញ្ជើញចូលរួមឱ្យបានកុះករ ហើយក៏ជាប្រវត្តិសាស្ត្រមួយ ដល់បងប្អូនខ្មែរជំនាន់ក្រោយ ។ "ដើម្បីនាំទឹកចូលស្រែ ត្រូវតែជីកប្រឡាយ" នេះជាពាក្យស្លោកមួយតែប៉ុណ្ណោះ ។

**កាលបរិច្ឆេទ:** ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៩ យប់ថ្ងៃ សៅរ៍ (On Saturday night, May02, 2009)

**ទីកន្លែង :** New Golden Palace
**801-21 Washington Ave**
**Philadelphia, PA 19147**
**Tel: 215-214-9239, 267-234-5303**

**ពេលវេលាចាប់ផ្តើម** ម៉ោង: 2PM – 4PM ការៈកិច្ចអស់នាយទាហាន នាយទាហានរង ពលទាហាន ទាំងអស់នៅទីកន្លែងខាងលើ ។
ម៉ោង: 4PM -10PM ចប់កម្មវិធី ។

ដូច្នេះហើយសូមអញ្ជើញបងប្អូនខ្មែររួមជាតិទាំងអស់ មកចូលរួម ហើយជួយឧបត្ថមដល់ការដ្ឋានខ្មែរយើងនេះឱ្យបានជោគជ័យ ដើម្បីធ្វើកិច្ចការទៅមុខទៀត ហើយនេះក៏ជាជំហានទីមួយដែរ ដែលខ្មែរយើងទើបតែជួបប្រទះ ។ បើលោកអ្នកចង់ឃើញព្រឹត្តិការណ៍នេះ សូមអញ្ជើញរួសរាន់មកចូលរួមតាមកាលបរិច្ឆេទខាងលើនេះ ។ ព័តមានបន្ថែម សូមមេត្តាទាក់ទងទៅទូរស័ព្ទ :

- លោក សិទ្ធិ ម៉ែន ប្រចាំរដ្ឋ PA លេខ: 215-214-9239 ឬ 267-234-5303
- លោក មិន ម៉ុនធារ៉េ ប្រចាំរដ្ឋ WA លេខ: 253- 227-2062 ឬ 253- 861-4205
- លោក ម៉ែន ណែម ប្រចាំរដ្ឋ MA លេខ: 978-551-7444
- អ្នកស្រី ចូរ៉ ប្រចាំរដ្ឋ CA លេខ: 562-489-4526

សូមអរគុណ




